ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ៩ លេខ ៩២ សប្តាហ៍ទី២ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៩

រាជកិច្ច

ផ្សាយចេញពី
ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់ថ្លៃជាមុន)

សារបាញ

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសំរេច សារាចរ ប្រកាស

ក

មាតិកា

I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

១-ព្រះរាជក្រម

៤-១២-២០០៩ -ព្រះរាជក្រម នស/រកម/១២០៩/០២៥ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពី ការធ្វើបាតុកម្មដោយសន្តិវិធី ៩២៦២

២-ព្រះរាជក្រឹត្យ

១-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១១៤ ស្តីពី ការតម្លើងថ្នាក់តាមសញ្ញាបត្រជូន ឯកឧត្តម តែន សត្ថា ពី ឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៦ ទៅជា ឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៥ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៩២៧៣

១-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១១៥ ស្តីពី ការតែងតាំង ឯកឧត្តម ឧត្តមសេនីយ៍ទោ ឡៅ ស៊ុនធា ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក ៩២៧៤

១-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១១៦ ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៧ រូប ៩២៧៥

១-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១១៧ ស្តីពី ការកែសម្រួលថ្នាក់ក្នុង ឋានន្តរស័ក្តិ ឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជូនមន្ត្រីរាជការ ចំនួន ០៤ រូប និងត្រូវបានតម្លើងទៅក្នុងឋានន្តរស័ក្តិ វរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជូនមន្ត្រីរាជការ ចំនួន ៣០ រូប ៩២៧៦

១-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១១៩ ស្តីពី ការតែងតាំង ឯកឧត្តម នូ សឿន ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក ៩២៧៨

១-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១២០ ស្តីពី ការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ឯក ជូនលោកឧត្តមសេនីយ៍ទោ លីច ម៉ូច នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៩២៧៩

១-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១២១ ស្តីពី ការតែងតាំងឥស្សរជនចំនួន ០២ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ៩២៨០

១-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១២២ ស្តីពី ការផ្ទេរលោក ចិន ងា ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ទៅក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ៩២៨១

០១-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១២៣ ស្តីពី ការតែងតាំងមន្ត្រីរាជការក្រសួងមហាផ្ទៃ ចំនួន ០២ រូប ៥២៨១

០១-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១២៤ ស្តីពី ការតែងតាំងទីប្រឹក្សាឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំនួន ០៣ រូប ៥២៨២

០៣-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១២៥ ស្តីពី ការតែងតាំងឯកឧត្តម លី យ៉ុងផាត់ ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ៥២៨៣

០៥-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១៣០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម,ឧកញ៉ា,លោកជំទាវ,អស់លោក និង លោកស្រី ចំនួន ៣៤ រូប ៥២៨៤

០៥-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១៣១ ស្តីពី ការប្រោសព្រះរាជទាន ចំពោះឯកឧត្តម ឧត្តមសេនីយ៍ឯក តាន់ បញ្ញាឫទ្ធ នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍនី ៥២៨៦

០៥-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១៣២ ស្តីពី ការតែងតាំង ឧត្តមសេនីយ៍ឯក គៀង សាវុធ ជាអគ្គមេបញ្ជាការរង នៃ កងយោធពលខេមរភូមិន្ទ ៥២៨៧

០៥-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១៣៤ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ត្រី ជូន នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០៦ រូប ៥២៨៨

០៥-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១៣៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម,លោកជំទាវ, និង អស់លោក ចំនួន ១០ រូប ៥២៨៩

០៥-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១៣៧ ស្តីពី ការដាក់ឱ្យឯកឧត្តម គ្រួច ផាន ឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៥ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ចូលនិវត្តន៍ ៥២៩០

០៥-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១៣៨ ស្តីពី ការតែងតាំងឯកឧត្តម គ្រួច ផាន ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៥២៩១

II. រាជរដ្ឋាភិបាល

អនុក្រឹត្យ

០៨-១២-២០០៩ -អនុក្រឹត្យលេខ ២១០ អនក្រ.បក ស្តីពី ការផ្ទេរគណនេយ្យទានថវិកា ៥២៩២

០៨-១២-២០០៩ -អនុក្រឹត្យលេខ ២១១ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៥២៩៤

០៨-១២-២០០៩ -អនុក្រឹត្យលេខ ២១២ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ១.៥៤៥ ហិកតា ស្ថិតក្នុងឃុំរំដោះស្រែ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ៥២៩៦

គ

៧-១២-២០០៩ -អនុក្រឹត្យលេខ ១៧១២ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ៩២៩៨

៧-១២-២០០៩ -អនុក្រឹត្យលេខ ១៧១៣ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីរាជការ ៩៣០៣

៨-១២-២០០៩ -អនុក្រឹត្យលេខ ១៧១៤ អនក្រ.តត ស្តីពី ការផ្ទេរក្របខ័ណ្ឌ នាយទាហាន ៩៣០៤

៨-១២-២០០៩ -អនុក្រឹត្យលេខ ១៧១៥ អនក្រ.តត ស្តីពី ការផ្ទេរក្របខ័ណ្ឌ នាយទាហាន ៩៣០៥

៨-១២-២០០៩ -អនុក្រឹត្យលេខ ១៧១៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៩៣០៦

៨-១២-២០០៩ -អនុក្រឹត្យលេខ ១៧១៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៩៣០៧

៨-១២-២០០៩ -អនុក្រឹត្យលេខ ១៧១៨ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៩៣១០

៨-១២-២០០៩ -អនុក្រឹត្យលេខ ១៧១៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩៣១១

៨-១២-២០០៩ -អនុក្រឹត្យលេខ ១៧២០ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៩៣១២

៨-១២-២០០៩ -អនុក្រឹត្យលេខ ១៧២១ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩៣១៣

៨-១២-២០០៩ -អនុក្រឹត្យលេខ ១៧២២ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៩៣១៤

៨-១២-២០០៩ -អនុក្រឹត្យលេខ ១៧២៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ. ៩៣១៦

៨-១២-២០០៩ -អនុក្រឹត្យលេខ ១៧២៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៩៣១៧

៩-១២-២០០៩ -អនុក្រឹត្យលេខ ១៧២៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៣១៩

៩-១២-២០០៩ -អនុក្រឹត្យលេខ ១៧២៦ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងនាយនគរបាលជាតិ ៩៣២០

៩-១២-២០០៩ -អនុក្រឹត្យលេខ ១៧២៧ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយស ៩៣២១

០-១២-២០០៩ -អនុក្រឹត្យលេខ ១៧២៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៩៣២៩

០-១២-២០០៩ -អនុក្រឹត្យលេខ ១៧២៩ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ៩៣៣០

០-១២-២០០៩ -អនុក្រឹត្យលេខ ១៧៣០ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៩៣៣២

III_ការងារបណ្តាក្រសួង

១_លិខិតរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

៩-១១-២០០៩ -ប្រកាសលេខ ១១០៦ ឧរថ.រសក.ប្រក ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅ នៃ នាយកដ្ឋាន វិញ្ញាបនបត្រកម្ម ៩៣៣៤

៩-១១-២០០៩ -ប្រកាសលេខ ១១០៧ ឧរថ.រសក.ប្រក ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅ នៃ នាយកដ្ឋាន បញ្ញត្តកម្ម និង វាយតម្លៃទទួលស្គាល់ ៩៣៤២

១-១២-២០០៩ -ប្រកាសលេខ ១១៩៧ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អល ស៊ូបភើ អ៊ីនធើប្រាយ (ខេមបូឌា) បង្កើតរោងចក្រផលិតសម្លៀកបំពាក់ ៩៣៥០

០១-១២-២០០៩ -ប្រកាសលេខ ១១៦៣ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន នីអាន់ យីដ (ខេមបូឌា) បង្កើតរោងចក្រផលិតសម្លៀកបំពាក់ ៩៣៥

០៣-១២-២០០៩ -ប្រកាសលេខ ១១៧៥ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ដុង ឡុង អ៊ិនធើប្រាយ បង្កើតរោងចក្រផលិតអំបោះ ៩៣៦

២. នីតិស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៥-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៥២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អេច & អិល គ្រុប ៩៣៦

២៥-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៥៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អ៊ីម៉ាហ្សេ & អាសូស្សេ ៩៣៦

២៥-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៥៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ឡូយ ស៊ុន ហ្វូត អ៊ីមផត អិចផត ៩៣៦

២៥-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៦១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ខេ (ខេមបូឌា) ៩៣៧

២៥-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៦៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ខេមបូឌាន ស្ការ អេជេនស៊ី (ស៊ីអេសអេ) ៩៣៧

២៥-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៦៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អេ.ខេ.អេច ៩៣៨

២៥-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៧០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ខូខេមដា គ្រុប ៩៣៨

២៦-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៧៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អេស អេស អិន គ្រុប ៩៣៨

២៦-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៧៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ទីតិចគូ ខូ អិលធីឌី ៩៣៨

២៦-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៧៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន តាំទី អ៊ិនធើណេសិនណល យ៉ាញ ចេនឈ័រ ខមភេនី (អាយ ខេ ទី) ៩៣៨

ព្រះរាជក្រម

នស/រកម/១២០៩/០២៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ច្បាប់

ស្តីពី

ការធ្វើបាតុកម្មដោយសន្តិវិធី

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

3/42.

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះ មានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅ នៃការធ្វើបាតុកម្មដោយសន្តិវិធី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.-

ច្បាប់នេះ មានគោលបំណង ធានាការពារសេរីភាពខាងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋខ្មែរ តាមរយៈការធ្វើបាតុកម្មដោយសន្តិវិធី ប៉ុន្តែមិនត្រូវឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាព និង កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គមជាតិ ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិឡើយ ។

មាត្រា ៣.-

ច្បាប់នេះ មានវិសាលភាពអនុវត្តលើរាល់ការប្រមូលផ្តុំគ្នា ឬ ការដង្ហែក្បួនធ្វើបាតុកម្មដោយសន្តិវិធី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែមិនអនុវត្តចំពោះ :

១-ការជួបប្រជុំ ឬ ការប្រមូលផ្តុំគ្នា ឬ ការហែក្បួនក្នុងយុទ្ធនាការឃោសនាបោះឆ្នោតណាមួយ ។

២-ការប្រមូលផ្តុំគ្នាខាងក្នុង និង ខាងក្រៅអែបប្រេះបរបងរោងចក្រ ឬ សហគ្រាស ឬ ស្ថាប័ននានា ពាក់ព័ន្ធនឹងវិវាទការងារ ដែលត្រូវដាក់បញ្ចូលក្នុងដែនអនុវត្តនៃច្បាប់ការងារ ។

៣-ការដើរហែក្បួនព្យុហយាត្រា ដើរហែសព និងការប្រមូលផ្តុំគ្នាដទៃទៀតក្នុងគោលបំណងបម្រើសាសនា សិល្បៈ វប្បធម៌ ទំនៀមទម្លាប់ប្រពៃណីជាតិ និងសកម្មភាពផ្សព្វផ្សាយអប់រំ ដើម្បីផលប្រយោជន៍សង្គម ។

មាត្រា ៤.-

បាតុកម្មដោយសន្តិវិធី សំដៅលើការប្រមូលផ្តុំគ្នា ឬ ការដង្ហែក្បួន ដោយមនុស្សមួយក្រុម ដើម្បីទាមទារ តវ៉ា ឬ សម្តែងជាសាធារណៈនូវមនោសញ្ចេតនា គំនិត ឬ ឆន្ទៈរបស់ក្រុមខ្លួនតាមរូបភាព ឬ មធ្យោបាយផ្សេងៗដោយសន្តិវិធី ។

ជំពូកទី ២
នីតិវិធីនៃការជូនដំណឹងអំពីការធ្វើបាតុកម្មដោយសន្តិវិធី

មាត្រា ៥.–

ក្រុមបុគ្គលណា ដែលមានបំណងរៀបចំធ្វើបាតុកម្មដោយសន្តិវិធី នៅទីកន្លែងសាធារណៈណាមួយ ត្រូវផ្ញើជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរដែនដីរាជធានី ឬ ខេត្ត មានសមត្ថកិច្ចគ្រប់គ្រងទីកន្លែងនោះ ។

មាត្រា ៦.–

លិខិតជូនដំណឹងនោះត្រូវបញ្ជាក់អំពី :

-នាមត្រកូល នាមខ្លួន និង អាសយដ្ឋានអចិន្ត្រៃយ៍ សម្រាប់ទំនាក់ទំនងរបស់អ្នកដឹកនាំចំនួនបី (៣)នាក់ ដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថតចម្លងផង

-គោលបំណងនៃការធ្វើបាតុកម្មដោយសន្តិវិធី

-កាលបរិច្ឆេទ ពេលវេលា និង រយៈពេល នៃការធ្វើបាតុកម្មដោយសន្តិវិធី ទីកន្លែង និង ផ្លូវដែលត្រូវប្រើប្រាស់សម្រាប់សកម្មភាព ចំនួនអ្នកចូលរួម ព្រមទាំងចំនួនយានជំនិះតាមប្រភេទនីមួយៗ ។

អ្នកដាក់លិខិតជូនដំណឹងទាំងអស់ត្រូវធានាថាគោរព ហើយអនុវត្តតាមតួនាទី និង ភារកិច្ចទទួលខុសត្រូវ ដូចមានចែងក្នុងមាត្រា ១៦ នៃច្បាប់នេះ ។

មាត្រា ៧.–

លិខិតជូនដំណឹងត្រូវដាក់នៅសាលារាជធានី ឬ សាលាខេត្ត យ៉ាងហោចណាស់ប្រាំ (៥)ថ្ងៃ នៃថ្ងៃធ្វើការងារមុនពេលកំណត់ នៃការធ្វើបាតុកម្មដោយសន្តិវិធី ។

មាត្រា ៨.–

នៅពេលបានទទួលលិខិតជូនដំណឹងហើយ សាលារាជធានី ឬ សាលាខេត្ត :

១-ត្រូវចេញបង្កាន់ដៃទទួលស្គាល់ជាលាយលក្ខណ៍អក្សរ ជូនអ្នកដែលបាន ដាក់លិខិតជូនដំណឹង ។

២-ត្រូវផ្សព្វផ្សាយលិខិតជូនដំណឹងនេះជាបន្ទាន់ នៅទីកន្លែងណាមួយ ដែលងាយមើលឃើញ នៅក្នុងអគាររដ្ឋបាល ឬ នៅក្នុងគេហទំព័រផ្លូវការរបស់ខ្លួន ។

៣-ត្រូវបញ្ជូនច្បាប់ថតចម្លងនៃលិខិតជូនដំណឹងនេះ ទៅស្នាក់ការនគរបាលមូលដ្ឋាន ស្នាក់ការកងរាជអាវុធហត្ថ និង អាជ្ញាធរមានសមត្ថកិច្ចដទៃទៀត ដែលមានការពាក់ព័ន្ធនឹងទីកន្លែងធ្វើបាតុកម្មនោះ ។

មាត្រា ៩.-

អាជ្ញាធរដែនដីរាជធានី ឬ ខេត្ត មានសមត្ថកិច្ចត្រូវឆ្លើយតបជាវិជ្ជមាន ចំពោះលិខិតជូនដំណឹងនោះជាលាយលក្ខណ៍អក្សរ លើកលែងតែ :

-ការធ្វើបាតុកម្មដោយសន្តិវិធី ត្រូវចំលើថ្ងៃប្រារព្ធព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ ព្រះរាជពិធីរាជាភិសេកព្រះមហាក្សត្រ ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក ពិធីបុណ្យឯករាជ្យជាតិ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ និងពិធីបុណ្យភ្ជុំបិណ្ឌ ។

-មានព័ត៌មានច្បាស់ថា ការធ្វើបាតុកម្មនេះនឹងអាចបង្កគ្រោះថ្នាក់ណាមួយ ឬ នឹងអាចប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ។

មាត្រា ១០.-

អាជ្ញាធរដែនដីរាជធានី ឬ ខេត្ត មានសមត្ថកិច្ចត្រូវពិនិត្យ និង ធ្វើការឆ្លើយតបវិញក្នុងរយៈពេលយ៉ាងយូរត្រឹមបី(៣)ថ្ងៃ នៃថ្ងៃការងារ ដោយគិតចាប់ពីថ្ងៃដែលលិខិតជូនដំណឹងត្រូវបានគេដាក់ជូន ។ ប្រសិនបើអាជ្ញាធរដែនដីរាជធានី ឬ ខេត្តមានសមត្ថកិច្ច ខកខានមិនបានឆ្លើយតបរហូតដល់ពេលកំណត់ដែលនឹងត្រូវធ្វើបាតុកម្មដោយសន្តិវិធី មានន័យថាអាជ្ញាធរដែនដីរាជធានី ឬ ខេត្តមានសមត្ថកិច្ច បានព្រមព្រៀងហើយ ។

មាត្រា ១១.-

ក្នុងករណីដែលអាជ្ញាធរដែនដីរាជធានី ឬ ខេត្ត មានសមត្ថកិច្ច មានព័ត៌មានច្បាស់ថា

ការធ្វើបាតុកម្មនេះ នឹងអាចបង្កគ្រោះថ្នាក់ណាមួយ ឬ នឹងអាចប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ អាជ្ញាធរដែនដីរាជធានី ឬ ខេត្ត ត្រូវធ្វើការឆ្លើយតប ដោយជូនដំណឹងជាបន្ទាន់ទៅអ្នកដែលបានដាក់លិខិតជូនដំណឹង ដើម្បីឱ្យពួកគេអាចមាន ពេលជួបជាមួយអាជ្ញាធរមូលដ្ឋាន និង អាជ្ញាធរពាក់ព័ន្ធដទៃទៀត ធ្វើការពិចារណាដើម្បី ពិភាក្សាគ្នាដោះស្រាយ ។

មាត្រា ១២.-

ក្រោយពីបានពិភាក្សាគ្នាហើយ បើភាគីទាំងពីរនៅតែមិនព្រមព្រៀងគ្នាទៀតនោះ អាជ្ញាធរដែនដីរាជធានី ឬ ខេត្តមានសមត្ថកិច្ច ត្រូវស្នើសុំយោបល់សម្រេចពីរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ។

មាត្រា ១៣.-

សេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និង ត្រូវ ផ្តល់ជូនដល់ម្ចាស់លិខិតជូនដំណឹងវិញ ក្នុងរយៈពេលយ៉ាងយូរម្ភៃបួន(២៤)ម៉ោង មុនពេល កំណត់នៃការធ្វើបាតុកម្មដោយសន្តិវិធី ។ ឯកសារថតចម្លងនៃការសម្រេច រួមទាំងព័ត៌មាន លំអិត នៃការកែប្រែដែលបានព្រមព្រៀងគ្នា ត្រូវផ្តល់ជូនទៅអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ និងជូនទៅអាជ្ញាធរដទៃទៀត ដែលមានតំបន់អាចនឹងទទួលរងនូវការប៉ះពាល់ ដោយសារ ការធ្វើបាតុកម្មដោយសន្តិវិធីនេះ ។

មាត្រា ១៤.-

មិនតម្រូវឱ្យមានការបញ្ជាក់ និងជានាសព្វគ្រប់ដូចមានចែងក្នុងមាត្រា ៦ កថាខណ្ឌទី ១ នៃច្បាប់នេះទេ ដោយគ្រាន់តែជូនដំណឹងជាលាយលក្ខណ៍អក្សរមានចុះហត្ថលេខា ឬ ស្នាម មេដៃ និងភ្ជាប់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថតចម្លង របស់អ្នកដឹកនាំធ្វើបាតុកម្មដោយ សន្តិវិធី ចំនួនបី(៣)នាក់ ដល់អាជ្ញាធរដែនដីរាជធានី ឬ ខេត្តមានសមត្ថកិច្ចនៅមូលដ្ឋាន នោះ យ៉ាងហោចណាស់ឱ្យ បានមុនដប់ពីរ(១២)ម៉ោងក្នុងថ្ងៃការងារ ឬ មុនសាមសិបប្រាំ មួយ(៣៦)ម៉ោងក្នុងថ្ងៃឈប់សម្រាក ប្រសិនបើការធ្វើបាតុកម្មដោយសន្តិវិធី ត្រូវបានគេធ្វើ ឡើងនៅតាមទីកន្លែងដូចខាងក្រោម :

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

7/124

១-នៅកន្លែងបញ្ចេញមតិជាសាធារណៈ ដែលបានបង្កើតឡើងយ៉ាងត្រឹមត្រូវតាមច្បាប់ ឬ តាមបទបញ្ញា ហើយដែលការធ្វើបាតុកម្មដោយសន្តិវិធីនោះ មានមនុស្សចូលរួមយ៉ាងច្រើនបំផុតត្រឹមពីររយ (២០០) នាក់ សម្រាប់រាជធានី ឬ ខេត្តនីមួយៗ ឬ

២-នៅកន្លែងដែលជាទ្រព្យសម្បត្តិឯកជន ឬ ជាទ្រព្យសម្បត្តិសមូហភាព ក្នុងករណីមានការយល់ព្រមពីម្ចាស់ទ្រព្យ ឬ ពីគណៈគ្រប់គ្រង ដែលជាអ្នកមើលការខុសត្រូវលើទ្រព្យសម្បត្តិសមូហភាពនោះ ហើយការធ្វើបាតុកម្មដោយសន្តិវិធីមានមនុស្សចូលរួមយ៉ាងច្រើនបំផុតត្រឹមពីររយ (២០០) នាក់ ។

ប៉ុន្តែ ក្នុងករណីដែលចំនួនក្រុមនៃការធ្វើបាតុកម្មដោយសន្តិវិធី មានចាប់ពី ពីរ(២) ក្រុមផ្សេងគ្នាឡើងទៅ ហើយចង់ធ្វើនៅកន្លែងតែមួយ និង ពេលវេលាតែមួយនោះ អាជ្ញាធរដែនដីរាជធានី ឬ ខេត្តមានសមត្ថកិច្ចត្រូវសម្រេចឱ្យក្រុមអ្នកដែលបានដាក់សេចក្តីជូនដំណឹងមុនទទួលបានសិទ្ធិធ្វើមុន ឬ អាចអនុញ្ញាតឱ្យធ្វើនៅកន្លែងមួយផ្សេងទៀត ដែលមានចម្ងាយយ៉ាងតិច ប្រាំរយ(៥០០)ម៉ែត្រ ។

ការធ្វើបាតុកម្មដោយសន្តិវិធី ដូចមានចែងក្នុងមាត្រានេះ អាចប្រព្រឹត្តទៅបាន តែក្នុងចន្លោះពេលពីម៉ោងប្រាំមួយ(៦)ព្រឹក ដល់ម៉ោងប្រាំមួយ(៦)ល្ងាចប៉ុណ្ណោះ ។

ជំពូកទី ៣
ការទទួលខុសត្រូវរបស់
អ្នកដឹកនាំធ្វើបាតុកម្ម និង អាជ្ញាធរមានសមត្ថកិច្ច

មាត្រា ១៥.-

ការធ្វើបាតុកម្មដោយសន្តិវិធី ដែលបានទទួលការព្រមព្រៀង មានការហែក្បួនលើផ្លូវសាធារណៈ អាជ្ញាធរដែនដីឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង ខេត្ត រាជធានី ឬ មន្ត្រីដែលត្រូវបានចាត់តាំងជាតំណាង ត្រូវសហការជាមួយនគរបាលមូលដ្ឋាន និង កងរាជអាវុធហត្ថ ដើម្បីទប់ស្កាត់ផលអាក្រក់ដែលនឹងអាចកើតមាន ដោយធ្វើការកំណត់ផ្លូវខាងលើឱ្យមានភាពងាយស្រួល និង សម្រួលចរាចរណ៍សម្រាប់យានយន្ត ដើម្បីកុំឱ្យមានការរំខានធ្ងន់ធ្ងរដល់ដំណើរការអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ឬ ជំនួញផ្សេងៗ ។

មាត្រា ១៦.-

អ្នកដឹកនាំធ្វើបាតុកម្មដោយសន្តិវិធី ត្រូវទទួលខុសត្រូវក្នុងការចាត់វិធានការសមស្រ
ដើម្បីរក្សាឱ្យបានថា ការធ្វើបាតុកម្មនេះ នឹងប្រព្រឹត្តទៅដោយសន្តិវិធី និង តាមលក្ខខណ្
ដូចខាងក្រោម :

១-ជូនដំណឹងដល់អ្នកចូលរួមអំពីការទទួលខុសត្រូវរបស់ខ្លួន ដូចមាន
ចែងក្នុងចំណុចទី ៣ នៃមាត្រានេះ ។

២-ពិភាក្សា និង សហការជាមួយមន្ត្រីមូលដ្ឋាន និង អាជ្ញាធរមានសមត្ថ-
កិច្ចដែលពាក់ព័ន្ធ ដើម្បីធានាឱ្យការធ្វើបាតុកម្មប្រព្រឹត្តទៅដោយសន្តិវិធី ។

៣-រក្សាសណ្តាប់ធ្នាប់របៀបរៀបរយឱ្យបានល្អ និង ត្រឹមត្រូវតាមពេលវេល
និង ទីកន្លែងកំណត់ គិតពីការចាប់ផ្តើមរហូតដល់ការបញ្ចប់ទៅវិញ នៃការធ្វើបាតុកម្មដោ
សន្តិវិធី ។

មាត្រា ១៧.-

អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់វិធានការការពារដល់ក្បួនបាតុកម្មដោយសន្តិវិ
ដើម្បីធានារក្សាសន្តិសុខ សុវត្ថិភាព និង សណ្តាប់ធ្នាប់សាធារណៈឱ្យបានល្អប្រសើរ ហើ
មិនត្រូវជ្រៀតជ្រែកដល់ការប្រព្រឹត្តទៅ នៃការធ្វើបាតុកម្មដោយសន្តិវិធីឡើយ ។

មាត្រា ១៨.-

នៅពេលមានការស្នើសុំជំនួយពីអ្នកដឹកនាំធ្វើបាតុកម្មដោយសន្តិវិធី អាជ្ញាធរមាន
សមត្ថកិច្ច ត្រូវខិតខំឆ្លើយតបដោយយកចិត្តទុកដាក់នូវសំណូមពរសមស្រប ដោយផ្អែកល
មូលដ្ឋានច្បាប់ ដើម្បីធានាដល់ការអនុវត្តសិទ្ធិសេរីភាពធ្វើបាតុកម្មដោយសន្តិវិធី និង ក
ប្រើប្រាស់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិជាសាធារណៈប្រកបដោយភាពថ្លៃថ្នូរ ។

មាត្រា ១៩.-

អាជ្ញាធរមានសមត្ថកិច្ច ដែលត្រូវបានចាត់តាំងឱ្យរក្សាសន្តិសុខ សុវត្ថិភា
សណ្តាប់ធ្នាប់សាធារណៈ នៅកន្លែងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវស្លៀកពាក់ឯកសណ្ឋា
ឱ្យបានត្រឹមត្រូវ ព្រមទាំងមានស្លាកឈ្មោះ និង អត្តលេខសម្គាល់ខ្លួន បង្ហាញនៅផ្ទៃ
ខាងមុខ និង ត្រូវប្រកាន់ខ្ជាប់នូវអត្តចរិតអត់ធ្មត់ដាច់ខាត ។

មាត្រា ២០.–

ការធ្វើបាតុកម្មដោយសន្តិវិធី ដែលមានការព្រមព្រៀង រាប់ទាំងការព្រមព្រៀង ដោយអាជ្ញាធរដែនដីរាជធានី ឬ ខេត្តមិនបានឆ្លើយតបដូចមានចែងក្នុងមាត្រា ១០ នៃច្បាប់នេះផង មិនត្រូវបានបំបែកទេ ។

ក្នុងករណីបាតុកម្មដោយសន្តិវិធី បានក្លាយជាអំពើហិង្សា អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់វិធានការសមស្រប ដើម្បីទប់ស្កាត់ និង បញ្ឈប់បាតុកម្មនេះជាបន្ទាន់ ។

ទោះបីជាបាតុកម្មប្រព្រឹត្តទៅដោយសន្តិវិធីក៏ដោយ ប៉ុន្តែបើមិនបានដាក់លិខិតជូនដំណឹងស្របតាមមាត្រា ៥ មាត្រា ៦ និង មាត្រា ១៤ នៃច្បាប់នេះ អាជ្ញាធរមានសមត្ថកិច្ចអាចចាត់វិធានការបញ្ឈប់បាតុកម្មនេះបាន ។

ជំពូកទី ៤
នីតិវិធីដោះស្រាយបទល្មើស និង ទោសប្បញ្ញត្តិ

មាត្រា ២១.–

ត្រូវធ្វើការព្រមានជាលាយលក្ខណ៍អក្សរ ចំពោះអ្នកដឹកនាំធ្វើបាតុកម្មដោយសន្តិវិធី ដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៩ មាត្រា ១៦ និង មាត្រា ២០ កថាខណ្ឌទី ២ និងទី ៣ នៃច្បាប់នេះ ។

មាត្រា ២២.–

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ចំពោះមន្ត្រីអាជ្ញាធរដែនដី ឬ មន្ត្រីអាជ្ញាធរមានសមត្ថកិច្ចណា ដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ១៧ មាត្រា ១៨ មាត្រា ១៩ និង មាត្រា ២០ កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នៃច្បាប់នេះ ។

មាត្រា ២៣.–

ក្នុងករណីបាតុករណាមានកាន់ឧបករណ៍ ដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ ឬ អាចបង្កទុក្ខទោសដល់អ្នកដទៃ ឬ ប្រព្រឹត្តអំពើណាមួយដែលជាការជ្រៀតជ្រែកសិទ្ធិសេរីភាពអ្នកដទៃ អាជ្ញាធរមានសមត្ថកិច្ចត្រូវដកហូតឧបករណ៍ទាំងនោះចេញ ឬ ហាមប្រាមកុំឱ្យបាតុករនោះប្រព្រឹត្តអំពើនេះទៀត ។ ប្រសិនបើជននោះមានការរឹងរូសមិនព្រមប្រគល់

ឱ្យ ឬ មិនព្រមឈប់ប្រព្រឹត្តអំពើនេះ សមត្ថកិច្ចត្រូវធ្វើការឃាត់ខ្លួនជាបណ្តោះអាសន្នរហូតដល់បាតុកម្មដោយសន្តិវិធីត្រូវបានបញ្ចប់សព្វគ្រប់ ទើបធ្វើការដោះលែងវិញ លើកលែងតែមានបទល្មើសអ្វីផ្សេងទៀត ។

មាត្រា ២៤.-

ក្នុងករណីបាតុករណាមានកាន់អាវុធ ឬ ជាតិផ្ទុះ អាជ្ញាធរមានសមត្ថកិច្ចត្រូវដកហូតអាវុធ ឬ ជាតិផ្ទុះទាំងនោះ និងធ្វើការឃាត់ខ្លួន រួចហើយបញ្ជូនទៅស្ថាប័នមានសមត្ថកិច្ចដើម្បីដោះស្រាយតាមច្បាប់ជាធរមាន ។

មាត្រា ២៥.-

ជនណាឆ្លៀតឱកាសក្នុងពេលធ្វើបាតុកម្មដោយសន្តិវិធី ដើម្បីប្រព្រឹត្តអំពើលួច ប្លន់ ឬ បណ្តាលឱ្យអន្តរាយទ្រព្យសម្បត្តិឯកជន ឬ ទ្រព្យសម្បត្តិសាធារណៈ ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

មាត្រា ២៦.-

ប្រសិនបើដំណើរការនៃការធ្វើបាតុកម្មដោយសន្តិវិធីបង្កជាអំពើហិង្សាបណ្តាលឱ្យអន្តរាយដល់ទ្រព្យសម្បត្តិឯកជនក្តី ឬ ទ្រព្យសម្បត្តិសាធារណៈក្តី ការជួសជុលការខូចខាតត្រូវជាបន្ទុករបស់ជនល្មើស និង អ្នកសមគំនិត ។

ក្នុងករណីអ្នកទាំងនោះមិនមានលទ្ធភាពធ្វើការជួសជុលការខូចខាត អាជ្ញាធរមានសមត្ថកិច្ចត្រូវបង្កសំណុំរឿងបញ្ជូនទៅតុលាការ ។

មាត្រា ២៧.-

បើដំណើរការនៃការធ្វើបាតុកម្មដោយសន្តិវិធី បង្កជាអំពើហិង្សា ជនណាដែលបានប្រព្រឹត្តល្មើសបណ្តាលឱ្យអាជ្ញាធរមានសមត្ថកិច្ច ឬ បាតុករ ឬ បុគ្គលដទៃទៀត មានរបួសស្នាម ឬ បណ្តាលឱ្យស្លាប់ ជននោះនឹងត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

ជំពូកទី៥

អន្តរប្បញ្ញត្តិ

មាត្រា ២៨.–

ក្នុងរយៈពេលប្រាំមួយ(៦)ខែ បន្ទាប់ពីច្បាប់នេះចូលជាធរមាន រាជធានី និង ខេត្តនីមួយៗត្រូវបង្កើត "កន្លែងបញ្ចេញមតិជាសាធារណៈ" ដោយត្រូវជ្រើសរើសទីធ្លា ឬ មណ្ឌលសមស្របមួយកន្លែងដែលមនុស្សទូទៅងាយស្តាប់ឮ និង មើលឃើញ នៅក្នុងទឹកដីនៃដែនសមត្ថកិច្ចរបស់ខ្លួន សម្រាប់ធ្វើបាតុកម្មដោយសន្តិវិធី ឬ បញ្ចេញមតិជាសាធារណៈ ដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ ។

ជំពូកទី៦

អវសានប្បញ្ញត្តិ

មាត្រា ២៩.–

ច្បាប់ស្តីពីបាតុកម្ម ដែលរដ្ឋសភានៃរដ្ឋកម្ពុជា បានអនុម័តនៅថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ១៩៩១ ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ១១៥ក្រ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៩១ និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣០.–

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៩

[illegible] ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា

ស ខេង

លេខ: ១០៦៧ ច.ល
ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១១៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សម្រេច

មាត្រា ១ : ត្រូវបានដំឡើងថ្នាក់តាមសញ្ញាបត្រជូន **ឯកឧត្តម ទែន សត្ថា** ពី ឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៦ ទៅជា ឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៥ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ។

មាត្រា ២ : បៀវត្សមូលដ្ឋានត្រូវបានអនុវត្តគិតចាប់ពីថ្ងៃចេញព្រះរាជក្រឹត្យនេះ ដោយរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើស និងវេនអតីតភាពឱ្យនៅដដែល ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ព.ល.០៩១២.១១៣៦

លេខ:១០៤០ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១១៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំង ឯកឧត្តម ឧត្តមសេនីយ៍ទោ **ឡៅ ស៊ុនឆាំ** អត្តលេខ ០១២៥ ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ:១០៥៥ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ធរល.០៩១២.១១៣៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩

[illegible] ហ៊ិនកេន

នស/រកត/១២០៩/១១១៦

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ព្រះរាជបញ្ញត្តិ

មាត្រា១ : ត្រូវបានដំឡើងឋានន្តរស័ក្តិ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

ក_ដំឡើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ឯក

-ឧត្តមសេនីយ៍ទោ ខ៊ែត នរិន្ទ អត្តលេខ ០០០២៣៥

ខ_ដំឡើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ

១-ឧត្តមសេនីយ៍ត្រី ម៉ូ ផាន់សារី អត្តលេខ ០០០៦១៣
២-ឧត្តមសេនីយ៍ត្រី ស៊ិរ ណាក់តើ អត្តលេខ ០០១១៥៨
៣-ឧត្តមសេនីយ៍ត្រី ជា សំអឿន អត្តលេខ ០០២១៣៧
៤-ឧត្តមសេនីយ៍ត្រី ទឹម សុខ អត្តលេខ ០០០៦១១
៥-ឧត្តមសេនីយ៍ត្រី អ៊ូ ផាន់ធី អត្តលេខ ០០០៦១២

គ_ដំឡើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ត្រី

-វរសេនីយ៍ឯក គន់ គីមប៊ិន អត្តលេខ ០០២១៤៤

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.០៩១២.១១៣៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩

លេខ:១០៣៩ ច.ល

ចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋាភិបាល

ឃុន ទិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានក្ខត្តិយា សាសនា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានកែសម្រួលថ្នាក់ក្នុង ឋានន្តរស័ក្តិ ឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជូនមន្ត្រីរាជការ ចំនួន ០៤ រូប ដូចមានរាយនាមខាងក្រោម :

១- **ឯកឧត្តម ឈិត សុខុន**	ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៥	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៣
២- **ឯកឧត្តម អ៊ុំ ម៉ុន**	ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៣
៣- **ឯកឧត្តម ស្រី មេន**	ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៣
៤- **ឯកឧត្តម មាស់ សារ៉ែត**	ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៣

មាត្រា ២ : ត្រូវបានដំឡើងទៅក្នុង ឋានន្តរស័ក្តិ វរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជូនមន្ត្រីរាជការ ចំនួន ៣០ រូប ដូចមានរាយនាមខាងក្រោម :

១- **ឯកឧត្តម អ៊ុយ ខេមរា**	ពី វរមន្ត្រី ថ្នាក់លេខ ១	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៣
២- **ឯកឧត្តម សែន សំគី**	ពី វរមន្ត្រី ថ្នាក់លេខ ១	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៣
៣- **ឯកឧត្តម ប្រាក់ សារឹុន**	ពី វរមន្ត្រី ថ្នាក់លេខ ១	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៣
៤- **ឯកឧត្តម ឌី គឹមសុក**	ពី វរមន្ត្រី ថ្នាក់លេខ ២	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៤
៥- **ឯកឧត្តម ម៉ិន សំអួល**	ពី វរមន្ត្រី ថ្នាក់លេខ ២	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៤
៦- **ឯកឧត្តម ប្រាក់ ស៊ីផារ៉ា**	ពី វរមន្ត្រី ថ្នាក់លេខ ២	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៤
៧- **ឯកឧត្តម កែវ សេន**	ពី វរមន្ត្រី ថ្នាក់លេខ ៤	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៥

៨-	ឯកឧត្តម ចន្ទ សុផល	ពី វរមន្ត្រី ថ្នាក់លេខ ៥	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៥
៩-	ឯកឧត្តម គីង ណែត	ពី វរមន្ត្រី ថ្នាក់លេខ ៥	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៥
១០-	ឯកឧត្តម ម៉ុក សារុយ	ពី វរមន្ត្រី ថ្នាក់លេខ ៥	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៥
១១-	ឯកឧត្តម ឡៅ មុនឌី	ពី វរមន្ត្រី ថ្នាក់លេខ ៥	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៥
១២-	ឯកឧត្តម ម៉ុន ស៊ើន	ពី វរមន្ត្រី ថ្នាក់លេខ ៦	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៦
១៣-	ឯកឧត្តម គុល សំអុល	ពី វរមន្ត្រី ថ្នាក់លេខ ៦	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៦
១៤-	ឯកឧត្តម ឈឹម នី	ពី វរមន្ត្រី ថ្នាក់លេខ ៦	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៦
១៥-	ឯកឧត្តម ឈាត់ ម៉ាត	ពី វរមន្ត្រី ថ្នាក់លេខ ៦	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៦
១៦-	ឯកឧត្តម ជិន ឈី	ពី វរមន្ត្រី ថ្នាក់លេខ ៦	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៦
១៧-	ឯកឧត្តម អ៊ុំ សារឿន	ពី វរមន្ត្រី ថ្នាក់លេខ ៦	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៦
១៨-	ឯកឧត្តម ស៊ុខ ផល	ពី វរមន្ត្រី ថ្នាក់លេខ ៦	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៦
១៩-	ឯកឧត្តម ម៉ែន សំបូរ	ពី វរមន្ត្រី ថ្នាក់លេខ ៦	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៦
២០-	ឯកឧត្តម សរ ម៉ុខ	ពី វរមន្ត្រី ថ្នាក់លេខ ៦	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៦
២១-	ឯកឧត្តម ម៉ុ មន្ត	ពី វរមន្ត្រី ថ្នាក់លេខ ៦	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៦
២២-	ឯកឧត្តម ជៀម តារី	ពី វរមន្ត្រី ថ្នាក់លេខ ៦	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៦
២៣-	ឯកឧត្តម នូ ផល្លា	ពី វរមន្ត្រី ថ្នាក់លេខ ៦	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៦
២៤-	ឯកឧត្តម ម៉ៅ ចន្ធី	ពី វរមន្ត្រី ថ្នាក់លេខ ៦	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៦
២៥-	ឯកឧត្តម ពិន សុខុន្ធា	ពី វរមន្ត្រី ថ្នាក់លេខ ៦	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៦
២៦-	ឯកឧត្តម ម៉េង ញ៉ាន់	ពី វរមន្ត្រី ថ្នាក់លេខ ៧	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៦
២៧-	ឯកឧត្តម អ៊ុន ណាស៊ី	ពី វរមន្ត្រី ថ្នាក់លេខ ៧	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៦
២៨-	ឯកឧត្តម លន់ ឈីមឆៃ	ពី វរមន្ត្រី ថ្នាក់លេខ ៧	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៦
២៩-	ឯកឧត្តម អ៊ូ សំអួន	ពី វរមន្ត្រី ថ្នាក់លេខ ៧	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៦
៣០-	ឯកឧត្តម នួន ម៉ុនថារ៉ាល់	ពី វរមន្ត្រី ថ្នាក់លេខ ៧	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៦

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

រ.ល.០៩១២.១១៣៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៥

លេខ:១០៤៩ ច.ល

ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៥

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

សំអុល ខឿសល

នស/រកត/១២០៩/១១១៩

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម នូ សឿន ជា ទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៤.០៩១២.១១៤១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩

លេខ:១០៤៣ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុំ ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៧០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បា ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោប ប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិក ដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនលោកឧត្តមសេនីយ៍ទោ **ឈឹម ម៉ុច** អត្តលេខ ០៤០ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោប បានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣.រ.ល.០៩៦២.១១៤២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩

លេខ:១០៤៥ច.ល

ជើងបង្ហាញចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុន ចិនកេង

ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៧១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោធភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឥស្សរជនចំនួន ០២ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **ឥត សារ៉ាត់**

២- ឯកឧត្តម **ម៉ក់ សារុន** ។

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ:១០៤៦ ច.ល

៣រ.ល.០៩១២.១១៨៣

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០០៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១២២

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានផ្ទេរ លោក **មិន ដា** ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ទៅក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

៣រល.០៩១២.១១៤៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩

លេខៈ ១០៣៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០ ខែ ធ្នូ ឆ្នាំ២០០
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១២៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិឧត្តោតរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំងមន្ត្រីរាជការក្រសួងមហាផ្ទៃចំនួន០២រូប ដូចមានរាយនាមខាងក្រោម :

១-ឯកឧត្តម **ធ្វី សុខហេង** ជាអនុប្រធានក្រុមប្រឹក្សានីតិកម្មក្រសួងមហាផ្ទៃ ថ្នាក់ស្មើអគ្គនាយក ជំនួសឯកឧត្តម **ផុន ម៉ុនថាល់** បច្ចុប្បន្នជាប្រធានក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ។

២-ឯកឧត្តម **ហ៊ិន យុទនា** ជាអនុប្រធានក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ ថ្នាក់ស្មើ **អគ្គនាយក** ។

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៣ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហត្ថលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣.៧.០៩១២.១១៤៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩

លេខ:១០៥៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឌិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងទីប្រឹក្សាឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំនួន ០៣រូប ដូចមានរាយនាមខាងក្រោម :

១-ឯកឧត្តម **អោម ចារាត់** មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បៀវត្ស
២-ឯកឧត្តម **ឆី សុខុន** មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បៀវត្ស
៣-ឯកឧត្តម **ខៀវ សុធ្វា** មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បៀវត្ស ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៩១២.១១៤៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩

លេខៈ ១០៤១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុំ ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១២៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រ្តពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម លី យ៉ុងផាត់ ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩៧.០៩២៨.១១២៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩

លេខ: ១០៤៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

...នកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៣០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជាតិរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១-ឯកឧត្តម ហ៊ុយ ហានសុង
២-លោកជំទាវឧកញ៉ា ខែ ណារិន
៣-ឯកឧត្តម អ៊ុង សួនស្មើ
៤-លោក ឡើង ប្រយុទ្ធ
៥-លោកវរសេនីយ៍ឯក ផាន់ ចណ្ណារ៉ែត
៦-លោក ហ៊ាង គង់ផេង
៧-លោកវរសេនីយ៍ត្រី ស សេរីទាសនា

ខ- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១-ឯកឧត្តម ច័ន្ទ សំអាន

គ- គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ ចំពោះ :

១-ឯកឧត្តម គឹម ខួន
២-ឯកឧត្តម ជា ម៉េងហួត
៣-ឯកឧត្តម តាំ សុខាន់
៤-ឯកឧត្តម នូ នឹម
៥-លោកឧត្តមសេនីយ៍ត្រី អ៊ុន សុចណ្ណធី
៦-លោក ចាន់ សាឡឿន

ឃ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :

១-ឯកឧត្តម តូច ជឿន
២-ឯកឧត្តម ហ៊ុន អៀង
៣-លោក តៅ រិទ្ធី
៤-លោកជំទាវ អ៊ុំ ច័ន្ទសុយ៉ារ៉ា
៥-លោក នួន គ្រិះស្នា
៦-លោក ឈឹម ចាន់ថា

ង- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ចំពោះ :

១-ឯកឧត្តមឧកញ៉ា ផ្ញើ សុចណ្ណារ៉ា

ច- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ :

១-ឯកឧត្តម សុខ ផេង
២-ឯកឧត្តម ចៅ ជីអាន
៣-លោកជំទាវ ចៅ ស៊ូអ៊ីង
៤-លោក ចៅ ជីទ៊ា

ឆ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

១-លោក សៀ ប៊ុនថន
២-លោកស្រី គុជ សោភា
៣-អ្នកនាង ថន លក្ខិណា
៤-លោកស្រី ហាឡូ ជៀក
៥-លោក ហេង ធីរៈ
៦-លោក អ៊ុំ ម៉ែន
៧-លោក ហួង សុគន្ធ
៨-លោក ចាន់ រិទ្ធី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.០៩១២.១១៥៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៩

លេខ:១០៥៧ជ.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ិន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៣១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តមឧត្តមសេនីយ៍ឯក តាន់ បញ្ញាវុធ

នូវ

គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៩១២.១១៥៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៩

លេខ:១០៦០ច.ល
សម្រាប់ចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៣៦

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្ដីពីការកែសំរួលតួនាទី ភារកិច្ច និងរចនា សម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំង ឧត្ដមសេនីយ៍ឯក **គៀង សាវុធ** អត្តលេខ ០០០០៣៥ ជា អគ្គមេបញ្ជាការរង នៃ កងយោធពលខេមរភូមិន្ទ ។

មាត្រា២ : សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៤.០៩១២.១១៥៧

លេខ:១០៦៤ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៩

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនភេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៣៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិ ថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានឈ្មោះខាងក្រោម :

១-លោកវរសេនីយ៍ឯក	ម៉ារ សំបូរណា	អត្តលេខ ០១៤៥១
២-លោកវរសេនីយ៍ឯក	អ៊ុំ សំអួន	អត្តលេខ ០១២៤៩
៣-លោកវរសេនីយ៍ឯក	ពៅ ទុន្នី	អត្តលេខ ០៩៩៤១
៤-លោកវរសេនីយ៍ឯក	ម៉ិច ចុន្ទ្រ	អត្តលេខ ៩៩១៥៤
៥-លោកវរសេនីយ៍ឯក	យស ភូមិរា	អត្តលេខ ០៧៩៩
៦-លោកវរសេនីយ៍ឯក	ថ្នាក់ ខាំ	អត្តលេខ ០៨០៤ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៩១៧.១១៥៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៩

លេខ: ១០៥៧ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៣៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក. គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១- ឯកឧត្តម គួក គឹមសាយ ៣- លោក ទេព សម្បត្តិ

២- លោក វ៉ិត ជិនបូរ៉ាជាតិ ៤- លោក យាម សុខណ្ណ

ខ. គ្រឿងឥស្សរិយយសសុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១- ឯកឧត្តម ខួយ គី ២- វរសេនីយ៍ទោ សុត ថុល អត្តលេខ : ០៣៥៧

គ. គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :

១- លោកជំទាវ ភង ធុន្នា ៣- លោកជំទាវ លឹម ចាន់ណា

២- លោកជំទាវ ខួង កញ្ញានា ៤- វរសេនីយ៍ទោ ចត់ គឹមសាន អត្តលេខ : ០៣៣៩៤៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣/ល.០៩១៤.១១៦០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ..ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៩

លេខ:១០៦៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៣៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
៥- លោក	ឡេង	ម៉ាន់	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.៩០០ ដុល្លារ
៦- លោក	ឌុច	អ៊ាត	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.៩៥០ ដុល្លារ

មាត្រា ២ .—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តតាកែវ និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:១៧២៦ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមុខតំណែងនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៩០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ម្រ េ ច

មាត្រា ១ : ត្រូវបានតែងតាំងមុខតំណែងលោក ឧត្តមសេនីយ៍ត្រី **ខាំ ឆា** អត្តលេខ ៦៤៤៦៨ ជាអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១៣២៣.អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការជូនគ្រឿងឥស្សរិយយស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកណ្តាល

ស ម្រេ ច

មាត្រា ១ : បំពាក់ **គ្រឿងឥស្សរិយយស** តាមប្រភេទ និងលំដាប់ថ្នាក់ ជូន ឥស្សរជន សប្បុរសជន មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធចំនួន **២០២ នាក់** ដែលមានស្នាដៃឆ្នើមក្នុងការបំពេញភារកិច្ច និងគុណបំណាច់ក្នុងការជួយកសាងសមិទ្ធផលគ្រប់វិស័យ រួមចំណែកស្តារ និងអភិវឌ្ឍន៍ ក្រុងតាខ្មៅ ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :

ក. មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

១-ឯកឧត្តម	**មួង**	**សៅខុន**	អនុរដ្ឋលេខាធិការមុខងារសាធារណៈ
២-ឯកឧត្តម	**សន**	**ស៊ីថន**	អគ្គនាយក ក្រសួងផែនការ
៣-ឯកឧត្តម	**គីម**	**ខួន**	ប្រធានសាខាគយ និង រដ្ឋាករ ខ័ណ្ឌ ៧ មករា
៤-ឯកឧត្តម	**នួវ**	**សាវ័ន**	កងឯកភាពអង្គរក្សសម្តេចនាយករដ្ឋមន្ត្រី
៥-ឯកឧត្តម	**វង្ស**	**សាម៉ុន**	អនុរដ្ឋលេខាធិការក្រសួងផែនការ
៦-ឯកឧត្តម	**សេង**	**សៀន**	អគ្គនាយករង ក្រសួងផែនការ

៧-លោកឧត្តមសេនីយត្រី ជៀម ឡាក់ កងឯកភាពអង្គរក្សសម្តេច នាយករដ្ឋមន្ត្រី
៨-ឯកឧត្តម នុត ចំនួនសុខា អនុរដ្ឋលេខាធិការ ក្រសួងផែនការ
៩-ឯកឧត្តម ឆួន ចុន្ថា ទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម
១០-ឯកឧត្តម ធូ សុភាព អគ្គលេខាធិការដ្ឋានក្រសួងផែនការ
១១-លោកវរសេនីយ៍ត្រី ហួយ ឈុនហ៊ុយ នាយរងការិយាល័យភស្តុភារ-គណនេយ្យ លេខាធិការដ្ឋាន នៃ អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ
១២-លោក នៅ ពិសិដ្ឋ កងឯកភាពអង្គរក្សសម្តេចនាយករដ្ឋមន្ត្រី
១៣-លោក អាយ ម៉េត មន្ត្រីសាខាគយរដ្ឋាករខេត្តកណ្តាល

ខ_ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :

១-លោក កែប ឆា មន្ត្រីគយ
២-ឯកឧត្តម ខៀវ សារី ទីប្រឹក្សាក្រសួងផែនការ
៣-លោក ឡុក ជ មន្ត្រីសាលាខេត្តកណ្តាល
៤-លោក ផៃ សុខន មន្ត្រីសាលាខេត្តកណ្តាល
៥-លោក រួន ឡុល មន្ត្រីសាលាខេត្តកណ្តាល
៦-លោក អ៊ី ស្រ៊ុន មន្ត្រីសាខាគយ និង រដ្ឋាករខេត្តកណ្តាល
៧-លោក ម៉ុន ចិន្តា មន្ត្រីសាខាគយ និង រដ្ឋាករខេត្តកណ្តាល
៨-លោក សួន ទិបុល មន្ត្រីសាខាគយ និង រដ្ឋាករខេត្តកណ្តាល
៩-លោក ចាម ជាតិ មន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
១០-លោក ខៀវ សំអាត មន្ត្រីគយ និង រដ្ឋាករ
១១-លោក អ៊ិន ឆនទឡ្សន៍ មន្ត្រីក្រសួងយុត្តិធម៌
១២-លោក មាស ហៀង អនុប្រធានមន្ទីរហិរញ្ញវត្ថុខេត្តកណ្តាល
១៣-លោក ទួន យន់ មន្ត្រីមន្ទីរហិរញ្ញវត្ថុខេត្តកណ្តាល
១៤-លោក ជុច ឆន មន្ត្រីមន្ទីរហិរញ្ញវត្ថុខេត្តកណ្តាល
១៥-លោក អ៊ី យូអេង មន្ត្រីមន្ទីរហិរញ្ញវត្ថុខេត្តកណ្តាល
១៦-លោក ចែន មុនី សមាជិកក្រុមប្រឹក្សាក្រុងតាខ្មៅ
១៧-លោក គេង ហៀង សប្បុរសជន
១៨-លោក នូ សុវណ្ណារិទ្ធ មន្ត្រីក្រសួងមហាផ្ទៃ
១៩-លោក នូ សុវណ្ណារ៉ា មន្ត្រីក្រសួងមហាផ្ទៃ
២០-លោក ជៀង វិចិត្រ មន្ត្រីសាលាក្រុងតាខ្មៅ
២១-លោក គីម តិច កងឯកភាពអង្គរក្សសម្តេចនាយករដ្ឋមន្ត្រី
២២-លោក ឈឿង ប៊ុនឆន មន្ត្រីនគរបាលខេត្តកណ្តាល

គ~ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :

១-កញ្ញា	ម៉ុន	រមណី	នាយសាលាក្រុងតាខ្មៅ
២-លោក	សុខ	វី	នាយរងសាលាក្រុងតាខ្មៅ
៣-លោក	កែវ	សារ៉ាយ	សមាជិកក្រុមប្រឹក្សាក្រុងតាខ្មៅ
៤-លោក	យ៉ឹន	បូរិន	ប្រធានការិយាល័យសង្គមកិច្ច យុវនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈក្រុងតាខ្មៅ
៥-លោក	សួស	វុន	អនុប្រធានការិយាល័យដែនដីនគរូបនីយកម្មសំណង់ និង ភូមិបាលក្រុងតាខ្មៅ
៦-លោក	សន	សឿង	មន្ត្រីចូលនិវត្តន៍
៧-លោក	ចាន់	ស៊ុន	ប្រធានការិយាល័យអប់រំយុវជន និងកីឡាក្រុងតាខ្មៅ
៨-លោក	អ៊ុច	សំអាង	មន្ត្រីការិយាល័យដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលក្រុងតាខ្មៅ
៩-លោក	នាន់	សេងឆេង	អនុប្រធានការិយាល័យអប់រំយុវជន និង កីឡាក្រុងតាខ្មៅ
១០-លោក	ខិន	ឡឿន	សមាជិកក្រុមប្រឹក្សាក្រុងតាខ្មៅ
១១-លោក	ម៉ូ	សុខែម	ប្រធានការិយាល័យអភិវឌ្ឍន៍ជនបទក្រុងតាខ្មៅ
១២-លោក	យាត	ឡេង	ចៅសង្កាត់ កំពង់សំណាញ់
១៣-លោក	អេង	ទន	ចៅសង្កាត់ ព្រែកឫស្សី
១៤-លោក	ហ៊ុង	សឿន	ចៅសង្កាត់ ដើមមៀន
១៥-លោក	ឡឹម	ខួយ	ចៅសង្កាត់ តាខ្មៅ
១៦-លោកស្រី	ជុំ	ស៊ុនួន	ចៅសង្កាត់ ព្រែកហូរ
១៧-លោកស្រី	ម៉ុន	ខ្ញឹមចាន់	ចៅសង្កាត់ តាក្តុល
១៨-លោកអនុសេនីយ៍ឯក	ញឹម សារ៉ា		នាយរងប៉ុស្តិ៍អន្តរជាតិភ្នំដិន
១៩-លោកអនុសេនីយ៍ឯក	ម៉ឺន នាយ		នាយរងប៉ុស្តិ៍អន្តរជាតិភ្នំដិន
២០-លោកអនុសេនីយ៍ឯក	ម៉ុន យ៉េន		នាយផ្នែកនៃនាយកដ្ឋានបុគ្គលិកក្រសួងមហាផ្ទៃ
២១-លោកអនុសេនីយ៍ឯក	ញៀម ខេមរា		ជំនួយការការិយាល័យទី៤ អាវុធហត្ថរាជធានីភ្នំពេញ
២២-លោក	អ៊ុំ	ណារិន	ប្រធានការិយាល័យហិរញ្ញវត្ថុសាលាក្រុងតាខ្មៅ
២៣-លោក	ទេព្វ	សិទ្ធី	សមាជិកក្រុមប្រឹក្សាក្រុងតាខ្មៅ
២៤-លោក	ខេង	សុខហេង	ប្រធានការិយាល័យកសិកម្មក្រុងតាខ្មៅ
២៥-លោក	យ៉ង់	ណារី	ប្រធានការិយាល័យព័ត៌មានក្រុងតាខ្មៅ
២៦-លោកស្រី	ហែម	គន្ធាឡៃ	អនុប្រធានមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តកណ្តាល
២៧-លោក	អ៊ិន	ឡេង	សមាជិកក្រុមប្រឹក្សាក្រុងតាខ្មៅ
២៨-លោកស្រី	ស៊ាម	សេដា	មន្ត្រីមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកណ្តាល
២៩-កញ្ញា	ឡុច	រ៉ានី	មន្ត្រីមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកណ្តាល

៣០-លោក	កែវ	សុគន្ធា	មន្ត្រីមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកណ្តាល
៣១-លោក	ស៊ុន	អឿង	សមាជិកក្រុមប្រឹក្សាក្រុងតាខ្មៅ
៣២-លោក	ឈូ	សាខន	មន្ត្រីការិយាល័យភូមិបាលក្រុងតាខ្មៅ
៣៣-លោក	ឃុន	ចាន់ថៃ	មន្ត្រីការិយាល័យភូមិបាលក្រុងតាខ្មៅ
៣៤-លោក	ឡិ	ផាន់ណា	អធិការនគរបាលក្រុងតាខ្មៅ
៣៥-លោក	ជុំ	ជួន	មន្ត្រីសាលាខេត្តកណ្តាល
៣៦-លោកស្រី	ម៉ុន	ពុទ្ធារឿន	អនុប្រធានការិយាល័យសង្គមកិច្ច
៣៧-លោកស្រី	ផាន់	សុខាន់	មន្ត្រីសាលាខេត្តកណ្តាល
៣៨-លោកស្រី	សារ៉េត	សារី	មន្ត្រីសាលាខេត្តកណ្តាល
៣៩-លោក	ស្វូ	ផាន់ណារិទ្ធ	មន្ត្រីសាលាខេត្តកណ្តាល
៤០-លោក	ពៅ	ឆាង	មន្ត្រីសាលាខេត្តកណ្តាល
៤១-លោក	ហុង	ពិស្ដា	មន្ត្រីសាលាខេត្តកណ្តាល
៤២-លោក	ម៉ាន់	សម្បត្តិ	មន្ត្រីសាលាខេតកណ្តាល
៤៣-លោក	កៀក	ណាយ	មន្ត្រីសាលាខេត្តកណ្តាល
៤៤-លោក	ពេជ	ឡុំ	មន្ត្រីសាលាខេត្តកណ្តាល
៤៥-លោក	អាត់	សំអាត	មន្ត្រីសាលាខេត្តកណ្តាល
៤៦-លោក	អ៊ីម	សុផុន	មន្ត្រីសាលាខេត្តកណ្តាល
៤៧-លោក	ហ៊ុន	សុខ	មន្ត្រីសាលាខេត្តកណ្តាល
៤៨-លោក	ឈុំ	អុន	មន្ត្រីសាលាខេតកណ្តាល
៤៩-លោក	ត្រាក់	ឆន	មន្ត្រីសាលាខេត្តកណ្តាល
៥០-លោក	ឆុន	ស៊ីដេត	មន្ត្រីសាលាខេត្តកណ្តាល
៥១-លោក	អ៊ុក	លីម	មន្ត្រីមន្ទីរទេសចរណ៍ខេត្តកណ្តាល
៥២-លោក	សោម	សេនា	មន្ត្រីការិយាល័យភូមិបាលក្រុងតាខ្មៅ
៥៣-លោកស្រី	ជាង	សៀង	សប្បុរសជន
៥៤-លោកវរសេនីយត្រី	ឆាន	ពិន	កងទ័ពជើងគោក
៥៥-លោក	ខៀម	យឿង	កងឯកភាពអង្គរក្សសម្តេចនាយករដ្ឋមន្ត្រី
៥៦-លោក	ជួប	សុភី	មន្ត្រីនគរបាលស្រុក
៥៧-លោក	ម៉ែន	ធី	សប្បុរសជន
៥៨-លោក	ផាត	ម៉ុង	មេបញ្ជាការផ្នែកសីករងក្រុងតាខ្មៅ
៥៩-លោក	ហៀង	ចន្ធី	មេបញ្ជាការកងរាជអាវុធហត្ថក្រុងតាខ្មៅ
៦០-លោកវរសេនីយ៍ត្រី	ញៀម	ដារ៉ា	អធិការនគរបាលស្រុកមណ្ឌលសីមា ខេត្តកោះកុង

ឃ~មេជាយមាសគារទារ :

១-លោក	សៀង	ឈន	មេភូមិ តាក្តុល សង្កាត់តាក្តុល
២-លោក	ទើង	រី	មេភូមិ ព្រែកកាត់ សង្កាត់តាក្តុល
៣-លោក	សែម	អ៊ុន	មេភូមិ ព្រែកឡុង សង្កាត់តាក្តុល
៤-លោក	ឈាង	សុខមេង	មេភូមិ ព្រែកឬស្សី សង្កាត់ព្រែកឬស្សី
៥-លោក	ជា	ឡៃ	មេភូមិ ក្រពើហា សង្កាត់ព្រែកឬស្សី
៦-លោក	គីម	នី	មេភូមិ ព្រែកអញ្ចាញ សង្កាត់ព្រែកឬស្សី
៧-លោក	តាន់	លៀង	មេភូមិ ដើមមៀន សង្កាត់ដើមមៀន
៨-លោក	ជុក	សារឿន	មេភូមិ ដើមគរ សង្កាត់ដើមមៀន
៩-លោក	អ៊ី	សុវណ្ណ	មេភូមិ ព្រែកតាពៅ សង្កាត់ដើមមៀន
១០-លោក	ហ៊ឹម	ឆុន	មេភូមិ ស្ទឹងជ្រៅ សង្កាត់ដើមមៀន
១១-លោក	យឹម	សុជា	មេភូមិ តាខ្មៅ សង្កាត់តាខ្មៅ
១២-លោក	នួច	សុខឿន	មេភូមិ ព្រែកសំរោង សង្កាត់តាខ្មៅ
១៣-លោក	គង់	សារឿន	មេភូមិថ្មី សង្កាត់តាខ្មៅ
១៤-លោក	នួយ	សាន	មេភូមិបត្តាជី សង្កាត់ព្រែកហូរ
១៥-លោក	អ៊ើ	ឈាង	មេភូមិព្រែកហូរកើត សង្កាត់ព្រែកហូរ
១៦-លោក	សុត	សុទ្ធី	មេភូមិព្រែកហូរលិច សង្កាត់ព្រែកហូរ
១៧-លោកស្រី	ខាន់	សារឿន	មេភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់
១៨-លោក	គង់	ចាន់យឿន	មេភូមិខ្ពបវែង សង្កាត់កំពង់សំណាញ់
១៩-លោក	យី	សារឿន	មេភូមិព្រែករាំង សង្កាត់កំពង់សំណាញ់
២០-លោក	នួក	ខៃ	មេភូមិក្របៅ សង្កាត់កំពង់សំណាញ់
២១-លោក	ជុំ	ចាន់ទាសនា	សមាជិកក្រុមប្រឹក្សាក្រុងតាខ្មៅ
២២-លោក	អោក	សំអុល	ជំនួយការស្មៀន សង្កាត់តាក្តុល
២៣-លោក	សរ	ណៃស្រៀង	អធិការនគរបាលក្រុងតាខ្មៅ
២៤-លោក	ទើន	និវន់	មន្ត្រីសាលាក្រុងតាខ្មៅ
២៥-លោក	ម៉ឿន	សាវ៉ន	មន្ត្រីសាលាក្រុងតាខ្មៅ
២៦-លោក	រស់	គេង	មន្ត្រីសាលាក្រុងតាខ្មៅ
២៧-លោក	ទីន	ទើង	មន្ត្រីសាលាក្រុងតាខ្មៅ
២៨-លោក	ឈឹម	សែម	មន្ត្រីការិយាល័យសាធារណៈការក្រុងតាខ្មៅ
២៩-លោក	ស៊ឹម	បូរិន	មន្ត្រីសាលាក្រុងតាខ្មៅ

៣០-លោកស្រី	ស៊ុង	ផេង	មន្ត្រីសាលាក្រុងតាខ្មៅ
៣១-លោក	ឌី	សុភន	មន្ត្រីនគរបាលក្រុងតាខ្មៅ
៣២-លោកស្រី	នាង	ឌួច	ជំទប់ទី១សង្កាត់ព្រែកហូរ
៣៣-លោក	ហាច្យ	អុំ	សមាជិកក្រុមប្រឹក្សាសង្កាត់ព្រែកហូរ
៣៤-លោក	យ៉េង	ហៀង	សមាជិកក្រុមប្រឹក្សាសង្កាត់ព្រែកហូរ
៣៥-លោក	សេង	ឈួន	សមាជិកក្រុមប្រឹក្សាសង្កាត់ព្រែកហូរ
៣៦-លោក	សាន់	យាត	ជំទប់ទី១សង្កាត់តាក្ដុល
៣៧-លោក	យ៉ាង	សំអុល	សមាជិកក្រុងប្រឹក្សាសង្កាត់តាក្ដុល
៣៨-លោកស្រី	ម៉េង	រ៉ាឌី	សមាជិកក្រុមប្រឹក្សាសង្កាត់តាក្ដុល
៣៩-លោក	ម៉ុន	ហ៊ុយ	ជំទប់ទី១សង្កាត់ព្រែកឫស្សី
៤០-លោក	សោម	ម៉ូ	សមាជិកក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី
៤១-លោក	ឆេង	ឆៃ	សមាជិកក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី
៤២-លោក	សាន	គួន	សមាជិកក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី
៤៣-លោក	ឯក	សំណាង	ជំទប់ទី១សង្កាត់ដើមមៀន
៤៤-លោកស្រី	ស្ងួន	ម៉ារឌី	សមាជិកក្រុមប្រឹក្សាសង្កាត់ដើមមៀន
៤៥-លោក	សែម	សឿន	សមាជិកក្រុមប្រឹក្សាសង្កាត់ដើមមៀន
៤៦-លោក	ស៊ុខ	ទុត្តា	សមាជិកក្រុមប្រឹក្សាសង្កាត់ដើមមៀន
៤៧-លោក	អាត់	ខណា	សមាជិកក្រុមប្រឹក្សាសង្កាត់ដើមមៀន
៤៨-លោក	ខន	ឃុន	ជំនួយការសង្កាត់ដើមមៀន
៤៩-លោកស្រី	ធី	ស៊ុខ	ជំទប់ទី១សង្កាត់កំពង់សំណាញ់
៥០-លោក	ស	ទ្រី	សមាជិកក្រុមប្រឹក្សាសង្កាត់កំពង់សំណាញ់
៥១-លោក	ឡាយ	ហោ	សមាជិកក្រុមប្រឹក្សាសង្កាត់កំពង់សំណាញ់
៥២-លោក	អ៊ឹម	អេម	សមាជិកក្រុមប្រឹក្សាសង្កាត់កំពង់សំណាញ់
៥៣-លោក	កែវ	ផាត់	ជំទប់ទី១សង្កាត់តាខ្មៅ
៥៤-លោក	ឃឹម	សុភិន	សមាជិកក្រុមប្រឹក្សាសង្កាត់តាខ្មៅ
៥៥-លោក	ឆាយ	ទី	សមាជិកក្រុមប្រឹក្សាសង្កាត់តាខ្មៅ
៥៦-លោក	ស៊ិន	ឌីណា	សមាជិកក្រុមប្រឹក្សាសង្កាត់តាខ្មៅ
៥៧-លោកស្រី	ជា	កែណារ៉ាត់	សមាជិកក្រុមប្រឹក្សាសង្កាត់តាខ្មៅ
៥៨-លោកស្រី	ម៉ៀច	ឡៃ	សមាជិកក្រុមប្រឹក្សាសង្កាត់តាខ្មៅ
៥៩-លោក	ស៊ីម	ហុង	ជំនួយការសង្កាត់តាខ្មៅ

៦០-លោកស្រី	ឈាន	សាវឿត	អនុប្រធានភូមិសង្កាត់តាក្តុល
៦១-លោក	ឡោ	ផុស	សមាជិកភូមិតាក្តុលសង្កាត់តាក្តុល
៦២-លោកស្រី	សៀក	មឿន	អនុប្រធានភូមិព្រៃកកាត់សង្កាត់តាក្តុល
៦៣-លោកស្រី	មួន	សុខា	សមាជិកភូមិព្រៃកកាត់សង្កាត់តាក្តុល
៦៤-លោក	ឈឹម	សុខឿន	អនុប្រធានភូមិព្រៃកឡុងសង្កាត់តាក្តុល
៦៥-លោកស្រី	ម៉ៅ	សាវ៉ន	សមាជិកព្រៃកឡុងសង្កាត់តាក្តុល
៦៦-លោក	ជួប	ចិន	អនុប្រធានភូមិក្រពើហាសង្កាត់ព្រៃកឬស្សី
៦៧-លោកស្រី	សុខ	ម៉ុនថា	សមាជិកភូមិក្រពើហាសង្កាត់ព្រៃកឬស្សី
៦៨-លោក	សំ	សារ៉ាត់	អនុប្រធានភូមិព្រៃកឬស្សីសង្កាត់ព្រៃកឬស្សី
៦៩-លោកស្រី	នុត	សាម៉ី	សមាជិកភូមិព្រៃកឬស្សីសង្កាត់ព្រៃកឬស្សី
៧០-លោក	ឈឹម	ធឿន	អនុប្រធានភូមិព្រៃកអញ្ចាញ សង្កាត់ព្រៃកឬស្សី
៧១-លោកស្រី	ឌុច	យ៉ុត	សមាជិកភូមិព្រៃកកអញ្ចាញ សង្កាត់ព្រៃកឬស្សី
៧២-លោក	ខួន	ឆាយ	អនុប្រធានភូមិដើមមៀន សង្កាត់ដើមមៀន
៧៣-លោក	ពៅ	ម៉ុណ្ណារី	សមាជិកភូមិដើមមៀន សង្កាត់ដើមមៀន
៧៤-លោក	គៀង	ឈាន	អនុប្រធានភូមិដើមគ សង្កាត់ដើមមៀន
៧៥-លោកស្រី	ចាន់	សារុំ	សមាជិកភូមិដើមគ សង្កាត់ដើមមៀន
៧៦-លោក	អើ	រឹម	អនុប្រធានភូមិព្រៃកតាពៅ សង្កាត់ដើមមៀន
៧៧-លោកស្រី	ខឹម	ផល្លីន	សមាជិកភូមព្រៃកតាពៅ សង្កាត់ដើមមៀន
៧៨-លោកស្រី	តុំ	ម៉ៃ	អនុប្រធានភូមិស្ទឹងជ្រៅ សង្កាត់ដើមមៀន
៧៩-លោក	ជួប	ម៉ុនធិន	សមាជិកភូមិស្ទឹងជ្រៅ សង្កាត់ដើមមៀន
៨០-លោក	ចៅ	សុខុន	អនុប្រធានភូមិតាខ្មៅ សង្កាត់តាខ្មៅ
៨១-លោកស្រី	ព្រាប	ស៊ុណារុន	សមាជិកភូមិតាខ្មៅ សង្កាត់តាខ្មៅ
៨២-លោក	គីម	ម៉េង	អនុប្រធានភូមិព្រៃកសំរោង សង្កាត់តាខ្មៅ
៨៣-លោកស្រី	សំ	សារឿន	សមាជិកភូមិព្រៃកសំរោង សង្កាត់តាខ្មៅ
៨៤-លោក	សោម	ស៊ីវ	អនុប្រធានភូមិថ្មី សង្កាត់តាខ្មៅ
៨៥-លោក	ធន់	ទូច	អនុប្រធានភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់
៨៦-លោកស្រី	ម៉ិន	ទូច	សមាជិកភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់
៨៧-លោក	ម៉ុំ	ចាន់	អនុប្រធានភូមិខ្ពបវែង សង្កាត់កំពង់សំណាញ់
៨៨-លោកស្រី	តូច	សុខគង់	សមាជិកភូមិខ្ពបវែង សង្កាត់កំពង់សំណាញ់
៨៩-លោកស្រី	ម៉ុត	តុត	អនុប្រធានភូមិព្រៃករាំង សង្កាត់កំពង់សំណាញ់

៩០-លោក	ម៉ុក	សុខហេង	សមាជិកភូមិព្រៃករាំង សង្កាត់កំពង់សំណាញ់
៩១-លោកស្រី	អឿន	ចាន់	អនុប្រធានភូមិក្របៅ សង្កាត់កំពង់សំណាញ់
៩២-លោក	ឈួន	ហុង	សមាជិកភូមិក្របៅ សង្កាត់កំពង់សំណាញ់
៩៣-លោកស្រី	ម៉ែន	សារឿន	អនុប្រធានភូមិបត្តាជី សង្កាត់ព្រែកហូរ
៩៤-លោក	កែម	វណ្ណៈ	សមាជិកភូមិបត្តាជី សង្កាត់ព្រែកហូរ
៩៥-លោក	ឌឹម	ចាន់ថន	អនុប្រធានភូមិព្រែកហូរលិច សង្កាត់ព្រែកហូរ
៩៦-លោកស្រី	ផេង	សុខ	សមាជិកភូមិព្រែកហូរលិច សង្កាត់ព្រែកហូរ
៩៧-លោកស្រី	សាន	សឿន	អនុប្រធានភូមិព្រែកហូរកើត សង្កាត់ព្រែកហូរ
៩៨-លោកស្រី	ឈើង	សុខឈាង	សមាជិកភូមិព្រែកហូរកើត សង្កាត់ព្រែកហូរ
៩៩-លោក	អាន	ណារិទ្ធ	ស្មៀនសង្កាត់ព្រែកឫស្សី សង្កាត់ព្រែកឫស្សី
១០០-លោក	គីម	ផល្លា	ស្មៀនសង្កាត់ព្រែកឫស្សី សង្កាត់ដើមមៀន
១០១-លោក	សំអាត	សុជាតិ	ស្មៀនសង្កាត់ព្រែកហូរ សង្កាត់ព្រែកហូរ
១០២-លោក	គង់	គីមឡឿន	ស្មៀនសង្កាត់កំពង់សំណាញ់ សង្កាត់កំពង់សំណាញ់
១០៣-លោក	សុភ	សុផា	ស្មៀនសង្កាត់តាខ្មៅ សង្កាត់តាខ្មៅ
១០៤-លោក	អ៊ំ	ប៊ុណា	កងឯកភាពអង្គរក្សសម្តេចនាយករដ្ឋមន្ត្រី
១០៥-លោក	យឹម	សាវុធ	កងឯកភាពអង្គរក្សសម្តេចនាយករដ្ឋមន្ត្រី
១០៦-លោក	ជា	ជ័យឈាម	មន្ត្រីសីករងក្រុងតាខ្មៅ
១០៧-លោក	ចេង	សុខ	មន្ត្រីសីករងក្រុងតាខ្មៅ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

__កន្លែងទទួល__ :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧៥៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូននាយនគរបាល ចំនួន០៤រូប នៃអង្គភាពការពារគោលដៅទី១ នាយកដ្ឋាននគរបាលការពារ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចការពារសន្តិសុខ សុវត្ថិភាពគោលដៅទីស្តីការគណៈរដ្ឋមន្ត្រី ដូចមានរាយនាមខាងក្រោម :-

១-វរសេនីយ៍ត្រី	អឿម ហេង	អត្តលេខ ០៩៣៩៣	ប្រធានផ្នែក
២-វរសេនីយ៍ត្រី	ស៊ុំ ចន្ថា	អត្តលេខ ០៧១៥៨	ប្រធានផ្នែក
៣-អនុសេនីយ៍ឯក	ខ៊ិត គឹមស៊ន	អត្តលេខ ០៧១៦៣	ប្រធានផ្នែក
៤-អនុសេនីយ៍ឯក	គង់ សុធា	អត្តលេខ ០៧២៦៣	ប្រធានផ្នែក

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧២៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ស ម្រេ ច

មាត្រា១ : ត្រូវបានដំឡើងឋានន្តរស័ក្តិលោក ហ៊ីទ បញ្ញាសិទ្ធិ ពីអនុមន្ត្រី ថ្នាក់លេខ ១០ ទៅវរមន្ត្រី ថ្នាក់លេខ ១០

នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
  ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ១៧៣០ . អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការដំឡើងឋានន្តរសក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរសក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ១៨នាក់ ដូចមានរាយនាមខាងក្រោម :

១-	លោកវរសេនីយ៍ទោ ញៀល ទុន	អត្តលេខ	០១០៨១
២-	លោកវរសេនីយ៍ទោ លឹម ហេន	អត្តលេខ	០១៧០៥
៣-	លោកវរសេនីយ៍ទោ លន ណារឡាម	អត្តលេខ	០១៧១៣
៤-	លោកវរសេនីយ៍ទោ ទុំ សុខ្លី	អត្តលេខ	០១៨១៨
៥-	លោកវរសេនីយ៍ទោ ហាស់ ស៊ីថា	អត្តលេខ	០១៨៧៨
៦-	លោកវរសេនីយ៍ទោ គុល ផាឈី	អត្តលេខ	០១៩៨០

៧- លោកវរសេនីយ៍ទោ ឡៀប ចាន់ធី អត្តលេខ ០២០៥២

៨- លោកវរសេនីយ៍ទោ ហេង សម្បត្តិ អត្តលេខ ០៣២៣៥

៩- លោកវរសេនីយ៍ទោ អ៊ឹម ឈុន អត្តលេខ ០៣៧៤៤

១០- លោកវរសេនីយ៍ទោ ឡឹក សុខា អត្តលេខ ០៤០៤២

១១- លោកវរសេនីយ៍ទោ អ៊ុំ សុផាន អត្តលេខ ០៤៩១៧

១២- លោកវរសេនីយ៍ទោ អ៊ុំ អម៉ារ៉ា អត្តលេខ ០៥៧៧២

១៣- លោកវរសេនីយ៍ទោ សែស ញ៉ៀន អត្តលេខ ០៨៥៤៣

១៤- លោកវរសេនីយ៍ទោ ឡុង ម៉ាលី អត្តលេខ ០៨៩៦៧

១៥- លោកវរសេនីយ៍ទោ គឹម ឃន អត្តលេខ ១០៧០១

១៦- លោកវរសេនីយ៍ទោ យិន ចំណាន អត្តលេខ ១២១៦៩

១៧- លោកវរសេនីយ៍ទោ នួច សំអុល អត្តលេខ ១៥៦៣៤

១៨- លោកវរសេនីយ៍ទោ ស សារ៉ាត អត្តលេខ ១៥៨៧៩ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>**កន្លែងទទួល**</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច* ✓
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ១១០៣ ឧរថ.វសក.ប្រក

ប្រកាស
ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ
នៃ នាយកដ្ឋានវិញ្ញាបនបត្រកម្ម

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីស្ដង់ដារកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃវិទ្យាស្ថានស្ដង់ដារកម្ពុជា
- ពិនិត្យសំណូមពរការងារចាំបាច់របស់ក្រសួង ។

សម្រេច

ប្រការ ១ : នាយកដ្ឋានវិញ្ញាបនបត្រកម្មស្ថិតនៅក្រោមការគ្រប់គ្រងនិងដឹកនាំផ្ទាល់របស់វិទ្យាស្ថានស្ដង់ដារកម្ពុជា និងមានភារកិច្ចដូចតទៅ :

-រៀបចំបែបបទនិងនីតិវិធីសម្រាប់ចេញវិញ្ញាបនបត្របញ្ជាក់ភាពអនុលោមតាមស្តង់ដារផលិតផល សុវត្ថិភាព និងប្រព័ន្ធគ្រប់គ្រងមានជាអាទិ៍ ISO 9001, ISO14001, ISO 22000, HACCP, GMP លើកលែងតែផលិតផលឱសថ បរិក្ខារពេទ្យ និងគ្រឿងសំអាង

-រៀបចំកិច្ចព្រមព្រៀងឬកិច្ចសន្យារបស់ក្រុមហ៊ុន រោងចក្រ សហគ្រាស និងអង្គភាពនានាពាក់ព័ន្ធនឹងការអនុវត្តតាមការតម្រូវនៃប្រព័ន្ធចេញវិញ្ញាបនបត្របញ្ជាក់ភាពអនុលោមតាមស្តង់ដារផលិតផល ឬ ប្រព័ន្ធគ្រប់គ្រង

-ធ្វើអធិការកិច្ចនៅក្នុងក្រុមហ៊ុន រោងចក្រ សហគ្រាស និងអង្គភាពនានាដែលបានស្នើសុំ និងដែលបានទទួលវិញ្ញាបនបត្របញ្ជាក់ភាពអនុលោមតាមស្តង់ដារផលិតផល

-ធ្វើសវនកម្មនៅក្នុងក្រុមហ៊ុន រោងចក្រ សហគ្រាស និងអង្គភាពនានា ដែលបានស្នើសុំ និងដែលបានទទួលវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធគ្រប់គ្រង

-ចូលរួមធ្វើសវនកម្មជាមួយអង្គភាពចេញវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធគ្រប់គ្រងនានាតាមការស្នើសុំ

-រៀបចំបែបបទ និង នីតិវិធីសម្រាប់ការពន្យារពេល ការព្យួរទុក ការដកហូត និងការលុបចោលវិញ្ញាបនបត្របញ្ជាក់ភាពអនុលោមតាមស្តង់ដារផលិតផល ឬ ប្រព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុន រោងចក្រ សហគ្រាស និងអង្គភាពនានា

-ចូលរួមជាមួយសមាគមក្រៅប្រទេស អង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិនានា ក្នុងការវាយតម្លៃភាពអនុលោម និងរៀបចំអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់ទៅវិញទៅមកដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ

-ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានវិទ្យាស្ថានប្រគល់ជូន។

ប្រការ ២ : នាយកដ្ឋានវិញ្ញាបនបត្រកម្ម ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

ប្រការ ៣ : នាយកដ្ឋានវិញ្ញាបនបត្រកម្ម មានរចនាសម្ព័ន្ធដូចតទៅ :

- ការិយាល័យរដ្ឋបាល
- ការិយាល័យវិញ្ញាបនបត្រកម្មផលិតផល
- ការិយាល័យវិញ្ញាបនបត្រកម្មប្រព័ន្ធគ្រប់គ្រង
- ការិយាល័យវិញ្ញាបនបត្រកម្មប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ

ការិយាល័យនិមួយៗ ដឹកនាំដោយប្រធានមួយរូបនិងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

អង្គការលេខរបស់នាយកដ្ឋានវិញ្ញាបនបត្រកម្មជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

ប្រការ ៤ : អំពីតួនាទី និង ភារកិច្ចរបស់ការិយាល័យនិមួយៗ :

១- **ការិយាល័យរដ្ឋបាល** :

តួនាទី :

ការិយាល័យរដ្ឋបាល ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានលើការគ្រប់គ្រងផ្នែករដ្ឋបាលរបស់នាយកដ្ឋាន ។

ភារកិច្ច :

-គ្រប់គ្រង និងបែងចែកលិខិតចេញ-ចូលរបស់នាយកដ្ឋាន

-គ្រប់គ្រងមន្ត្រី-បុគ្គលិកក្នុងនាយកដ្ឋាន

-រៀបចំពិធីការក្នុងការទទួលភ្ញៀវ សិក្ខាសាលា វគ្គបណ្តុះបណ្តាល កិច្ចប្រជុំ និងពិធីផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការងាររបស់នាយកដ្ឋាន

-គ្រប់គ្រងនិងត្រួតពិនិត្យការធ្វើចរាចរលិខិត ឯកសារគ្រប់ប្រភេទ របស់នាយកដ្ឋាន

-លើកគម្រោងចំណាយប្រចាំឆ្នាំ និងគម្រោងផ្សេងទៀតរបស់នាយកដ្ឋាន

-គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ និងធ្វើបញ្ជីសារពើភ័ណ្ឌរបស់នាយកដ្ឋាន

-វាយតម្លៃការអនុវត្តការងាររបស់ការិយាល័យជំនាញនិមួយៗចំណុះនាយកដ្ឋាន

-បូកសរុបនិងធ្វើរបាយការណ៍អំពីសកម្មភាពនានារបស់នាយកដ្ឋាន.។

២- **ការិយាល័យវិញ្ញាបនបត្រកម្មផលិតផល** :

តួនាទី :

ការិយាល័យវិញ្ញាបនបត្រកម្មផលិតផល ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានលើការងារចេញវិញ្ញាបនបត្របញ្ជាក់ភាពអនុលោមតាមស្តង់ដារផលិតផល ។

ភារកិច្ច :

-រៀបចំក្បួនប្រតិបត្តិសំរាប់ចេញវិញ្ញាបនបត្រផលិតផលតាមគោលការណ៍ណែនាំអន្តរជាតិស្តីពីការតម្រូវទូទៅសំរាប់អង្គភាពប្រតិបត្តិប្រព័ន្ធវិញ្ញាបនបត្រផលិតផល

-រៀបចំលក្ខណៈវិនិច្ឆ័យសំរាប់ការជ្រើសរើសអធិការរបស់ការិយាល័យវិញ្ញាបនបត្រកម្មផលិតផល

-រៀបចំកិច្ចព្រមព្រៀង ឬ កិច្ចសន្យាសំរាប់ក្រុមហ៊ុន រោងចក្រ សហគ្រាស និងសិប្បកម្មនានាពាក់ព័ន្ធនឹងការអនុវត្តតាមការតម្រូវនៃប្រព័ន្ធចេញវិញ្ញាបនបត្រផលិតផល

-ចុះធ្វើអធិការកិច្ចនិងយកគំរូផលិតផលនៅក្នុងក្រុមហ៊ុន រោងចក្រ សហគ្រាស និងសិប្បកម្មនានាដែលបានដាក់ពាក្យស្នើសុំវិញ្ញាបនបត្រផលិតផល

-ចុះអង្កេតនិងយកគំរូផលិតផលតាមកម្មវិធីកំណត់នៅក្នុងក្រុមហ៊ុន រោងចក្រ សហគ្រាស និងសិប្បកម្មនានាដែលបានទទួលវិញ្ញាបនបត្រផលិតផល

-ចុះស៊ើបអង្កេតនិងយកគំរូផលិតផលនៅក្នុងក្រុមហ៊ុន រោងចក្រ សហគ្រាស និងសិប្បកម្មនានាដែលបានទទួលវិញ្ញាបនបត្រផលិតផលនៅពេលមានព័ត៌មាន ឬ ករណីផ្សេងៗកើតឡើងពាក់ព័ន្ធនឹងផលិតផល

-រៀបចំបែបបទ និង នីតិវិធីសំរាប់ការពន្យារពេល ការព្យួរទុក ការដកហូត និងការលុបចោលវិញ្ញាបនបត្រផលិតផលរបស់ក្រុមហ៊ុន រោងចក្រ សហគ្រាស និងសិប្បកម្មនានា

-រៀបចំកិច្ចព្រមព្រៀងសំរាប់ប្រើវិញ្ញាបនបត្រនិងអាជ្ញាប័ណ្ណប្រើសញ្ញាស្តង់ដារ ចំពោះផលិតផលដែលអនុលោមតាមស្តង់ដារកម្ពុជា

-តាមដានការប្រើប្រាស់វិញ្ញាបនបត្រផលិតផលនិងអាជ្ញាប័ណ្ណប្រើសញ្ញាស្តង់ដារ ចំពោះផលិតផលដែលបានអនុលោមតាមស្តង់ដារកម្ពុជា

-រៀបចំនីតិវិធីសំរាប់ដោះស្រាយការតវ៉ា បណ្តឹង និងជម្លោះលើការចេញវិញ្ញាបនបត្រផលិតផល

-ធ្វើសវនកម្មផ្ទៃក្នុងនិងការពិនិត្យឡើងវិញលើការគ្រប់គ្រង

-រៀបចំកិច្ចព្រមព្រៀងសំរាប់ប្រើប្រាស់អធិការ និង មន្ទីរពិសោធន៍ពីខាងក្រៅ

-រៀបចំនីតិវិធីសំរាប់ចុះបញ្ជីអធិការក្នុងក្របខ័ណ្ឌនៃការងារចេញវិញ្ញាបនបត្រផលិតផល

-ទទួលបន្ទុកក្នុងកិច្ចសហការជាមួយសមាគមអាស៊ាននិងអង្គភាពពាក់ព័ន្ធនានា ក្នុងការវាយតម្លៃភាពអនុលោម និងរៀបចំអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់ទៅវិញទៅមក

-រៀបចំកម្មវិធីបណ្តុះបណ្តាលរបស់ការិយាល័យ ។

៣- <u>ការិយាល័យវិញ្ញាបនបត្រកម្មប្រព័ន្ធគ្រប់គ្រង</u> :

<u>តួនាទី</u> :

ការិយាល័យវិញ្ញាបនបត្រកម្មប្រព័ន្ធគ្រប់គ្រង ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានលើការងារចេញវិញ្ញាបនបត្របញ្ជាក់ភាពអនុលោមតាមស្តង់ដារប្រព័ន្ធគ្រប់គ្រង លើកលែងតែស្តង់ដារប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ ។

<u>ភារកិច្ច</u>:

-រៀបចំក្បួនប្រតិបត្តិតាមគោលការណ៍ណែនាំអន្តរជាតិស្តីពីការតម្រូវសំរាប់អង្គភាពធ្វើសវនកម្ម និងផ្តល់វិញ្ញាបនបត្រលើប្រព័ន្ធគ្រប់គ្រង ដូចជា ISO 9001, ISO 14001, OHSAS 18001,

SA 8000 ។ល។

-រៀបចំកិច្ចព្រមព្រៀង ឬ កិច្ចសន្យារបស់ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម និងអង្គភាពនានាពាក់ព័ន្ធនឹងការអនុវត្តតាមការតម្រូវនៃប្រព័ន្ធចេញវិញ្ញាបនបត្របញ្ជាក់ភាពអនុលោមតាមស្តង់ដារប្រព័ន្ធគ្រប់គ្រង

-ចុះធ្វើសវនកម្មនៅក្នុងក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម និងអង្គភាពនានាដែលបានដាក់ពាក្យស្នើសុំវិញ្ញាបនបត្រ

-ចុះធ្វើសវនកម្មអង្កេតនៅក្នុងក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម និងអង្គភាពនានាដែលបានទទួលវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ

-ចុះធ្វើសវនកម្មឡើងវិញនៅក្នុងក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម និងអង្គភាពនានាដែលសុំបន្តវិញ្ញាបនបត្រ

-ចូលរួមធ្វើសវនកម្មជាមួយអង្គភាពចេញវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធគ្រប់គ្រងនានាតាមការស្នើសុំ

-រៀបចំបែបបទ និង នីតិវិធីសម្រាប់ការពន្យារពេល ការព្យួរទុក ការដកហូត និងការលុបចោលវិញ្ញាបនបត្របញ្ជាក់ភាពអនុលោមតាមប្រព័ន្ធខាងលើរបស់ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម និងអង្គភាពនានា ដែលមិនគោរពតាមលក្ខខណ្ឌនិងកិច្ចព្រមព្រៀងដែលបានកំណត់

-រៀបចំកិច្ចព្រមព្រៀងសំរាប់ការប្រើវិញ្ញាបនបត្រនិងប្រើសញ្ញាស្តង់ដារកម្ពុជា

-រៀបចំកិច្ចព្រមព្រៀងសំរាប់ការប្រើប្រាស់សវនករនិងអ្នកជំនាញការបច្ចេកទេសមកពីខាងក្រៅ

-រៀបចំកិច្ចព្រមព្រៀងសំរាប់ការប្រើប្រាស់អង្គភាពវិញ្ញាបនបត្រកម្មមកពីខាងក្រៅ ក្នុងសកម្មភាពចេញវិញ្ញាបនបត្រ

-រៀបចំនីតិវិធីសំរាប់ដោះស្រាយការតវ៉ា បណ្តឹង និងជម្លោះលើការចេញវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ

-រៀបចំនីតិវិធីសំរាប់ចុះបញ្ជីសវនករទៅតាមជំនាញនិមួយៗ ក្នុងក្របខណ្ឌនៃការងារចេញវិញ្ញាបនបត្រ

-រៀបចំកម្មវិធីបណ្តុះបណ្តាលរបស់ការិយាល័យ ។

៤- ការិយាល័យវិញ្ញាបនបត្រកម្មប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ :

តួនាទី :

ការិយាល័យវិញ្ញាបនបត្រកម្មប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានលើការងារចេញវិញ្ញាបនបត្របញ្ជាក់ភាពអនុលោមតាមគោលការណ៍ណែនាំស្តីពីក្បួនអនុវត្តផលិតកម្មល្អ(GMP) គោលការណ៍ណែនាំស្តីពីប្រព័ន្ធសុវត្ថិភាពម្ហូបអាហារ(HACCP) ស្តង់ដារប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ(ISO 22000) និងគោលការណ៍ណែនាំនានាពាក់ព័ន្ធទៅនឹង

សុវត្ថិភាពម្ហូបអាហារ ។

ភារកិច្ច :

-រៀបចំក្បួនប្រតិបត្តិសំរាប់ប្រព័ន្ធចេញវិញ្ញាបនបត្របញ្ជាក់ភាពអនុលោមតាមគោលការណ៍ណែនាំស្តីពីក្បួនអនុវត្តផលិតកម្មល្អ(GMP) គោលការណ៍ណែនាំស្តីពីប្រព័ន្ធសុវត្ថិភាពម្ហូបអាហារ (HACCP) និងស្តង់ដារប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ(ISO 22000) និងគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងសុវត្ថិភាពម្ហូបអាហារ

-រៀបចំកិច្ចព្រមព្រៀង ឬ កិច្ចសន្យារបស់ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម និងអង្គភាពនានាពាក់ព័ន្ធនឹងការអនុវត្តតាមការតម្រូវនៃប្រព័ន្ធចេញវិញ្ញាបនបត្របញ្ជាក់ភាពអនុលោមតាមស្តង់ដារនិងគោលការណ៍ណែនាំខាងលើ

-ចុះធ្វើសវនកម្មនៅក្នុងក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម និងអង្គភាពនានាដែលបានដាក់ពាក្យស្នើសុំវិញ្ញាបនបត្រ

-ចុះធ្វើសវនកម្មអង្កេតនៅក្នុងក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម និងអង្គភាពនានាដែលបានទទួលវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធខាងលើ

-ចុះធ្វើសវនកម្មឡើងវិញនៅក្នុងក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម និងអង្គភាពនានាដែលសុំបន្តវិញ្ញាបនបត្រ

-ចូលរួមធ្វើសវនកម្មជាមួយអង្គភាពចេញវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធគ្រប់គ្រងនានាតាមការស្នើសុំ

-រៀបចំបែបបទ និង នីតិវិធីសម្រាប់ការពន្យារពេល ការព្យួរទុក ការដកហូត និងការលុបចោលវិញ្ញាបនបត្របញ្ជាក់ភាពអនុលោមតាមប្រព័ន្ធខាងលើរបស់ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម និងអង្គភាពនានា ដែលមិនគោរពតាមលក្ខខណ្ឌនិងកិច្ចព្រមព្រៀងដែលបានកំណត់

-រៀបចំកិច្ចព្រមព្រៀងសំរាប់ការប្រើវិញ្ញាបនបត្រនិងប្រើសញ្ញាស្តង់ដារកម្ពុជា

-រៀបចំកិច្ចព្រមព្រៀងសំរាប់ការប្រើប្រាស់សវនករនិងអ្នកជំនាញការបច្ចេកទេសមកពីខាងក្រៅ

-រៀបចំកិច្ចព្រមព្រៀងសំរាប់ការប្រើប្រាស់អង្គភាពវិញ្ញាបនបត្រកម្មមកពីខាងក្រៅក្នុងសកម្មភាពចេញវិញ្ញាបនបត្រ

-រៀបចំនីតិវិធីសំរាប់ដោះស្រាយការតវ៉ា បណ្តឹង និងជម្លោះលើការចេញវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធខាងលើ

-រៀបចំនីតិវិធីសំរាប់ចុះបញ្ជីសវនករទៅតាមជំនាញនិមួយៗក្នុងក្របខ័ណ្ឌនៃការងារចេញវិញ្ញាបនបត្រខាងលើ

- រៀបចំកម្មវិធីបណ្តុះបណ្តាលរបស់ការិយាល័យ ។

ប្រការ ៥ : រាល់ប្រកាស និងសេចក្តីសម្រេចទាំងឡាយណាដែលមានន័យផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវ

ធាត់ទុកជានិរាករណ៍ ។

ប្រការ ៦ : អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ និងប្រធាននាយកដ្ឋានវិញ្ញាបនបត្រកម្ម មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួនតាមប្រកាសនេះ ។

ប្រការ ៧ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០០៩

រដ្ឋមន្ត្រី

ស៊ុយ សែម

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
  " ដើម្បីជូនជ្រាប "
- គ្រប់នាយកដ្ឋានសេនាធិការក្រសួង
- គ្រប់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលរាជធានី-ខេត្ត
  " ដើម្បីជ្រាបជាព័ត៌មាន "
- ដូចប្រការ៦ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

តារាងឧបសម្ព័ន្ធ នៃប្រកាសលេខ : ១១០៣-ភ្ចជ.ទ័ស.ក្រក
ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ២០០៩

អង្គការលេខរបស់នាយកដ្ឋានវិញ្ញាបនបត្រកម្ម



បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ២០០៩
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ស៊ុយ_សែម

បានឃើញ និង ពិនិត្យត្រឹមត្រូវ
រាជធានីភ្នំពេញ, ថ្ងៃទី 30 ខែ កញ្ញា ឆ្នាំ២០០៩
ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា

ពិន ស៊ីវនព្រាយ

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០០៩
ប្រធាននាយកដ្ឋានវិញ្ញាបនបត្រកម្ម

សេង_ឆាង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

លេខ : ១១០៧ ឧរថ.វសក.ប្រក

ប្រកាស

ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃ នាយកដ្ឋានបញ្ញត្តកម្ម និង វាយតម្លៃទទួលស្គាល់

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត /០៩០៨ /១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ៣៥អនក្រ បក ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញ អនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃវិទ្យាស្ថានស្តង់ដារកម្ពុជា
- ពិនិត្យសំណូមពរការងារចាំបាច់របស់ក្រសួង ។

សម្រេច

ប្រការ ១ : នាយកដ្ឋានបញ្ញត្តកម្មនិងវាយតម្លៃទទួលស្គាល់ ស្ថិតក្រោមការគ្រប់គ្រងនិងដឹកនាំផ្ទាល់របស់វិទ្យាស្ថានស្តង់ដារកម្ពុជា និងមានភារកិច្ចដូចតទៅ :

- រៀបចំបង្កើតសញ្ញាស្តង់ដារកម្ពុជា
- រៀបចំបែបបទ និង នីតិវិធី សម្រាប់ការចុះបញ្ជីផលិតផលប្រើសញ្ញាស្តង់ដារកម្ពុជា តាមការស្នើសុំ

- រៀបចំបែបបទ និង នីតិវិធី សម្រាប់ការចេញអាជ្ញាប័ណ្ណបញ្ជាក់ផលិតផល តាមការស្នើសុំ
- រៀបចំបែបបទ និង នីតិវិធី សម្រាប់ការចុះបញ្ជី និងចេញវិញ្ញាបនបត្រ... សម្រាប់ការចុះបញ្ជី និងចេញទិដ្ឋាការចំពោះបុគ្គលឬអង្គភាពណាមួយដែលមានបំណងផ្សព្វផ្សាយពាណិជ្ជកម្មអំពីការទទួលបានវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធគ្រប់គ្រងណាមួយលើកលែងតែផលិតផលឱសថ បរិក្ខារពេទ្យ និងគ្រឿងសំអាង
- រៀបចំ និងគ្រប់គ្រងស្តង់ដារ និងបញ្ជាក់មុខសញ្ញា និង/ឬស្តង់ដារប្រើប្រាស់សារធាតុគីមីក្នុងវិស័យឧស្សាហកម្ម តាមការស្នើសុំ
- រៀបចំបែបបទ និង នីតិវិធីសម្រាប់ការចេញលិខិតបញ្ជាក់ទំនិញនាំចូល ចំពោះផលិតផលដែលត្រូវអនុលោមតាមបញ្ញត្តិបច្ចេកទេស ឬស្តង់ដារបញ្ជា តាមតម្រូវការរបស់សមត្ថកិច្ចពាក់ព័ន្ធ និងតាមការស្នើសុំ
- រៀបចំកិច្ចព្រមព្រៀង ឬកិច្ចសន្យាពាក់ព័ន្ធនឹងការប្រើអាជ្ញាប័ណ្ណ
- ចុះធ្វើអធិការកិច្ច តាមការកំណត់ដូចមានចែងក្នុងមាត្រា៧ និងមាត្រា៨ នៃច្បាប់ស្តីពីស្តង់ដារកម្ពុជា
- រៀបចំបែបបទ និង នីតិវិធី សម្រាប់ការពន្យារពេល ការព្យួរទុក ការដកហូត និងការលុបចោលអាជ្ញាប័ណ្ណ
- ជំរុញឱ្យផលិតផលមានការប្រើប្រាស់ស្តង់ដារ និងមានការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព ព្រមទាំងជំរុញការប្រកួតប្រជែងត្រឹមត្រូវនៅក្នុងការធ្វើពាណិជ្ជកម្ម
- រៀបចំគោលការណ៍ណែនាំ និងផ្តល់យោបល់ក្នុងការកំណត់ស្តង់ដារបញ្ជា ឬបញ្ញត្តិបច្ចេកទេស
- សិក្សា ស្រាវជ្រាវ និងផ្សព្វផ្សាយអំពីផលិតផល ទំនិញ សម្ភារៈដែលមានភាពគ្រោះថ្នាក់ដល់សុខភាព សុវត្ថិភាព បរិស្ថាន និងទ្រព្យសម្បត្តិសង្គម ដោយសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ
- ចូលរួមក្នុងការអនុវត្តកិច្ចព្រមព្រៀងពាក់ព័ន្ធជាមួយអង្គភាពបញ្ញត្តកម្មអន្តរជាតិ តំបន់ និងប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិនានា ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ
- រៀបចំបែបបទ និង នីតិវិធីសម្រាប់ចេញវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីអង្គភាពវាយតម្លៃភាពអនុលោម មន្ទីរពិសោធន៍ធ្វើតេស្តឬក្រិតខ្នាត អង្គភាពបណ្តុះបណ្តាលសម្រាប់ការវាយតម្លៃភាពអនុលោម និងបុគ្គលណាមួយដែលមានលក្ខណសម្បត្តិដើម្បីវាយតម្លៃភាពអនុលោម
- មិនត្រូវបានអនុញ្ញាតឱ្យធ្វើការវាយតម្លៃទទួលស្គាល់ ចំពោះអង្គភាពវាយតម្លៃភាពអនុលោម និងមន្ទីរពិសោធន៍ដែលនៅចំណុះវិទ្យាស្ថានឡើយ
- រៀបចំកិច្ចព្រមព្រៀង ឬកិច្ចសន្យារបស់អង្គភាពវាយតម្លៃភាពអនុលោម មន្ទីរពិសោធន៍ធ្វើតេស្តឬក្រិតខ្នាត អង្គភាពបណ្តុះបណ្តាលសម្រាប់ការវាយតម្លៃភាពអនុលោម និងបុគ្គលណាមួយដែលមានលក្ខណសម្បត្តិដើម្បីវាយតម្លៃភាពអនុលោមពាក់ព័ន្ធនឹងការអនុវត្តតាមការតម្រូវនៃប្រព័ន្ធចេញវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជី
- ធ្វើសវនកម្មក្នុងអង្គភាពវាយតម្លៃភាពអនុលោម មន្ទីរពិសោធន៍ធ្វើតេស្តឬក្រិតខ្នាត អង្គភាពបណ្តុះបណ្តាលសម្រាប់ការវាយតម្លៃភាពអនុលោម និងបុគ្គលណាមួយដែលមានលក្ខណសម្បត្តិដើម្បីវាយតម្លៃភាពអនុលោមដែលស្ថិតនៅក្រៅក្របខ័ណ្ឌរបស់វិទ្យាស្ថាន និងដែលបានស្នើសុំ និងដែលបានទទួលវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជី

- រៀបចំបែបបទ និង នីតិវិធី សម្រាប់ការពន្យារពេល ការព្យួរទុក ការដកហូត និងការលុបចោលវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជី
- ចូលរួមសហការជាមួយសមាគមក្រៅប្រទេស អង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិនានាក្នុងការវាយតម្លៃទទួលស្គាល់ និងចុះបញ្ជី និងរៀបចំអនុវត្តកិច្ចព្រមព្រៀងនានា
- ទទួលអនុវត្តការកិច្ចផ្សេងទៀតដែលប្រធានវិទ្យាស្ថានប្រគល់ជូន ។

ប្រការ ២ : នាយកដ្ឋានបញ្ញត្តកម្ម និងវាយតម្លៃទទួលស្គាល់ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

ប្រការ ៣ : នាយកដ្ឋានបញ្ញត្តកម្ម និងវាយតម្លៃទទួលស្គាល់ មានរចនាសម្ព័ន្ធដូចតទៅ :

- ការិយាល័យរដ្ឋបាល
- ការិយាល័យបញ្ញត្តកម្ម
- ការិយាល័យគ្រប់គ្រងសារធាតុគីមី
- ការិយាល័យអធិការកិច្ច
- ការិយាល័យវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ និងការចុះបញ្ជី

ការិយាល័យនីមួយៗដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់

អង្គការលេខរបស់នាយកដ្ឋានបញ្ញត្តកម្មនិងវាយតម្លៃទទួលស្គាល់ ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

ប្រការ ៤ : អំពីតួនាទី និងភារកិច្ចរបស់ការិយាល័យនីមួយៗ :

១-<u>ការិយាល័យរដ្ឋបាល</u>

<u>តួនាទី:</u>

ការិយាល័យរដ្ឋបាល ជាអង្គភាពសេនាធិការជំនួយការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានលើការងាររដ្ឋបាល បូកសរុបសកម្មភាពការងារដែលនាយកដ្ឋានបានអនុវត្ត ។

<u>ភារកិច្ច:</u>

- ការងារ គ្រប់គ្រងលិខិតចេញ-ចូល និងបញ្ជូនលិខិត
- រៀបចំកម្មវិធីការងារប្រចាំថ្ងៃរបស់នាយកដ្ឋាន
- រៀបចំធ្វើបដិសណ្ឋារកិច្ចក្នុងនាយកដ្ឋាន
- គ្រប់គ្រងបញ្ជីវត្តមាន-អវត្តមាន
- គ្រប់គ្រងចលនទ្រព្យ និងអចលនទ្រព្យ ឯកសារ និងការងារបណ្ណាល័យរបស់នាយកដ្ឋាន
- រៀបចំផែនការការងារដោយសហការជាមួយការិយាល័យផ្សេងទៀតក្នុងនាយកដ្ឋានលើការងារបណ្តុះបណ្តាល
- វាយតម្លៃការអនុវត្តការងាររបស់ការិយាល័យជំនាញនីមួយៗចំណុះនាយកដ្ឋាន

- លើកគំរោងចំណាយថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍បូកសរុបការងាររបស់នាយកដ្ឋាន
- រៀបចំទីកន្លែង និង ឯកសារសំរាប់គ្រប់ការងារប្រជុំ
- រៀបចំធ្វើបញ្ជីកត់ត្រាលម្អិតអំពីវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីទាំងឡាយដែលបាន រៀបចំដោយនាយកដ្ឋាន ។

២-**ការិយាល័យបញ្ញត្តកម្ម**

តួនាទី:

ការិយាល័យបញ្ញត្តកម្ម ជាអង្គភាពសេនាធិការជំនួយការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានលើការងាររៀបចំបញ្ញត្តិ និង បទប្បញ្ញត្តិបច្ចេកទេសពាក់ព័ន្ធនឹងស្តង់ដារូបនីយកម្ម ។

ភារកិច្ច:

- រៀបចំបង្កើតសញ្ញាស្តង់ដារកម្ពុជា សម្រាប់ផលិតផលឬទំនិញ ឬសម្រាប់ផលិតកម្ម ខ្សែសង្វាក់ផលិតកម្ម ការ កែច្នៃ ឬប្រព្រឹត្តិកម្មលើផលិតផលឬទំនិញ ឬសេវាកម្ម ឬសម្រាប់ប្រព័ន្ធណាមួយ
- ជំរុញឱ្យផលិតផលមានការប្រើប្រាស់សញ្ញាស្តង់ដារ និងមានការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព ព្រមទាំង ជំរុញការប្រកួតប្រជែងត្រឹមត្រូវនៅក្នុងការធ្វើពាណិជ្ជកម្ម
- រៀបចំបែបបទ និង នីតិវិធី សម្រាប់ការចុះបញ្ជីផលិតផលប្រើសញ្ញាស្តង់ដារកម្ពុជា
- រៀបចំបែបបទ និង នីតិវិធី សម្រាប់ការចេញអាជ្ញាប័ណ្ណបញ្ជាក់ការចុះបញ្ជីផលិតផល
- រៀបចំកិច្ចព្រមព្រៀង ឬកិច្ចសន្យាពាក់ព័ន្ធនឹងការប្រើអាជ្ញាប័ណ្ណ
- រៀបចំបែបបទ និងនីតិវិធី សម្រាប់ការពន្យារពេល ការព្យួរទុក ការដកហូត និងការលុបចោលអាជ្ញាប័ណ្ណ
- តាមដាន និង អង្កេតលើការប្រើប្រាស់អាជ្ញាប័ណ្ណ
- រៀបចំប្រកាសរួមរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីកំណត់ ការបង់កម្រៃក្នុងការស្នើសុំអាជ្ញាប័ណ្ណ
- រៀបចំបែបបទ និង នីតិវិធីសម្រាប់ការចុះបញ្ជី និងចេញទិដ្ឋាការចំពោះបុគ្គល ឬអង្គភាពណាមួយដែលមាន បំណងផ្សព្វផ្សាយពាណិជ្ជកម្មអំពីការទទួលបានវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធគ្រប់គ្រងណាមួយ
- សិក្សា ស្រាវជ្រាវ និងផ្សព្វផ្សាយអំពីផលិតផល ទំនិញ សម្ភារៈដែលមានភាពគ្រោះថ្នាក់ដល់សុខភាព សុវត្ថិភាព បរិស្ថាន និងទ្រព្យសម្បត្តិសង្គម ដោយសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ
- រៀបចំគោលការណ៍ណែនាំ និងផ្តល់យោបល់ក្នុងការកំណត់ស្តង់ដារបញ្ជា ឬបញ្ញត្តិបច្ចេកទេស
- ទទួលបន្ទុកសម្របសម្រួលការងារគ្រប់គ្រងហានិភ័យរបស់ក្រសួង
- ចូលរួមក្នុងការអនុវត្តកិច្ចព្រមព្រៀងពាក់ព័ន្ធជាមួយអង្គភាពបញ្ញត្តកម្មអន្តរជាតិ តំបន់ និងប្រទេសជាសមាជិក អង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិនានា ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ

- តាមដាន និង អង្កេតលើការប្រើប្រាស់សញ្ញាស្តង់ដារកម្ពុជា
- រៀបចំបែបបទ និង នីតិវិធីសម្រាប់ការចេញលិខិតបញ្ជាក់ទំនិញនាំចូល ចំពោះផលិតផលដែលត្រូវអនុលោមតាមបញ្ញត្តិបច្ចេកទេស ឬស្តង់ដារបញ្ជា តាមតម្រូវការរបស់សមត្ថកិច្ចពាក់ព័ន្ធ ។

៣-ការិយាល័យគ្រប់គ្រងសារធាតុគីមី

តួនាទី:

ការិយាល័យគ្រប់គ្រងសារធាតុគីមីជាអង្គភាពសេនាធិការជំនួយការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានលើការងារគ្រប់គ្រងសារធាតុគីមី ។

ភារកិច្ច:

- រៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រគ្រប់គ្រងសារធាតុគីមី
- រៀបចំគោលការណ៍ក្នុងការគ្រប់គ្រង និងប្រើប្រាស់សារធាតុគីមី
- គ្រប់គ្រងការអនុវត្តក្នុងការប្រើស្លាកសញ្ញាសារធាតុគីមី
- រៀបចំការបញ្ជាក់មុខសញ្ញា និងស្តង់ដារប្រើប្រាស់សារធាតុគីមីក្នុងវិស័យឧស្សាហកម្ម
- រៀបចំ និង គ្រប់គ្រងស្តង់ដារប្រើប្រាស់សារធាតុគីមីក្នុងវិស័យឧស្សាហកម្ម
- រៀបចំបែបបទ និង នីតិវិធីចុះបញ្ជីសារធាតុគីមីដែលផលិត និងប្រើប្រាស់ក្នុងស្រុក នាំចូល និងនាំចេញ
- ទទួលបន្ទុកសម្របសម្រួលការងារគ្រឿងញៀនរបស់ក្រសួង
- ចូលរួមសហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងការទប់ស្កាត់ការបង្វែរសារធាតុគីមីពីជំនួញត្រឹមត្រូវស្របច្បាប់យកទៅប្រើប្រាស់ក្នុងសកម្មភាពខុសច្បាប់ (ការបំពុលបរិស្ថាន ការផលិតគ្រឿងញៀន ការបំផ្លិសកម្មភាព ភេរវកម្ម ការផលិតអាវុធគីមី ជីវសាស្ត្រ ។ល។) ។

៤-ការិយាល័យអធិការកិច្ច

តួនាទី:

ការិយាល័យអធិការកិច្ច ជាអង្គភាពសេនាធិការជំនួយការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានលើការងារចុះធ្វើអធិការកិច្ចតាមការកំណត់ដូចមានចែងក្នុងច្បាប់ស្តីពីស្តង់ដារកម្ពុជា ។

ភារកិច្ច:

- រៀបចំបែបបទ និង នីតិវិធីសំរាប់ការធ្វើអធិការកិច្ច ស្របតាមច្បាប់ស្តីពីស្តង់ដារកម្ពុជា
- ពិនិត្យនិងយកគំរូផលិតផលឬទំនិញ ឬសម្ភារៈ ឬសារធាតុដែលបានប្រើប្រាស់ ឬដែលសង្ស័យថានឹងយកមកប្រើប្រាស់ក្នុងកម្មន្តសាល
- បើកកញ្ចប់ឬកុងតឺន័រណាដែលមានផ្ទុក ឬ ដែលសង្ស័យថាមានផ្ទុកផលិតផលឬទំនិញ ឬសម្ភារៈ ឬសារធាតុចំពោះផលិតផលឬទំនិញ :

ដែលស្នើសុំអាជ្ញាប័ណ្ណ ឬ

. ដែលមានប្រើសញ្ញាស្តង់ដារដោយគ្មានអាជ្ញាប័ណ្ណ ឬ

. ដែលមានអាជ្ញាប័ណ្ណហើយ តែត្រូវសង្ស័យថាបានផលិតឬបានកែច្នៃក្នុងផលិតកម្មដែលមិនអនុលោម

តាមស្តង់ដារពាក់ព័ន្ធ ឬ

. ដែលត្រូវឱ្យអនុលោមតាមស្តង់ដារបញ្ជា

- ចុះធ្វើអធិការកិច្ចតាមក្រុមហ៊ុន ដែលមានប្រើពាក្យស្តង់ដារកម្ពុជា ឬ អក្សរកាត់ ISC

- ចុះធ្វើអធិការកិច្ចតាមក្រុមហ៊ុន ដែលផ្សព្វផ្សាយពាណិជ្ជកម្មអំពីការទទួលវិញ្ញាបនប័ត្របញ្ជាក់ប្រព័ន្ធណាមួយ

- ចុះធ្វើអធិការកិច្ច និងស្រាវជ្រាវអំពីផលិតផលដែលមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន

- ចូលរួមសហការជាមួយស្ថាប័នពាក់ព័ន្ធនានាក្នុងការធ្វើអធិការកិច្ច លើការងារពាក់ព័ន្ធ

- ជ្រើសរើសបុគ្គលិកដែលមានសមត្ថភាពក្នុងនាយកដ្ឋាន ដើម្បីស្នើសុំចាត់តាំងពីប្រធានវិទ្យាស្ថាន ឱ្យបំពេញការងារជាអធិការស្របតាមច្បាប់ស្តីពីស្តង់ដារកម្ពុជា

- ជ្រើសរើសបុគ្គលិកផ្សេងទៀតដែលមានសមត្ថភាព ដើម្បីស្នើសុំចាត់តាំងពីប្រធានវិទ្យាស្ថានឱ្យបំពេញការងារជាអធិការស្របតាមច្បាប់ស្តីពីស្តង់ដារកម្ពុជា

- រក្សាទុកឱ្យបានសមស្របតាមបច្ចេកទេសនូវគំរូផលិតផល ឬទំនិញ ឬ សម្ភារៈ ឬសារធាតុដែលបានប្រើប្រាស់ ឬ ដែលសង្ស័យថានឹងយកមកប្រើប្រាស់ក្នុងកម្មន្តសាលដែលបានយកមកដោយអធិការ ដើម្បីធ្វើការពិសោធន៍

- គ្រប់គ្រង និង ពិនិត្យឯកសារដែលអធិការបានប្រមូល និងធ្វើការវាយតម្លៃលើលទ្ធផលនៃការធ្វើអធិការកិច្ច ដើម្បីដាក់ជូនថ្នាក់ដឹកនាំពិនិត្យនិងសំរេច

- រៀបចំមន្ទីរពិសោធន៍សម្រាប់ធ្វើតេស្តជាបឋម

- រក្សានូវការសម្ងាត់រាល់ឯកសារនិងលទ្ធផលនៃការវិភាគផ្សេងៗដែលទទួលបានពីការធ្វើអធិការកិច្ច។

៥-ការិយាល័យវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ និងការចុះបញ្ជី

តួនាទី:

ការិយាល័យវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់និងការចុះបញ្ជី ជារចនាសម្ព័ន្ធអាជ្ញាធិការជំនួយការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានលើការងារចេញវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ឬវិញ្ញាបនបត្រចុះបញ្ជី។

ភារកិច្ច:

- រៀបចំបែបបទ និង នីតិវិធីសម្រាប់ចេញវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ឬវិញ្ញាបនបត្រចុះបញ្ជីអង្គភាពវាយតម្លៃភាពអនុលោម មន្ទីរពិសោធន៍ធ្វើតេស្តឬក្រិតខ្នាត អង្គភាពបណ្តុះបណ្តាលសម្រាប់ការវាយតម្លៃភាពអនុលោម បុគ្គលណាមួយដែលមានលក្ខណសម្បត្តិដើម្បីវាយតម្លៃភាពអនុលោម និងសេវាកម្មនានា លើកលែងតែអង្គភាពវាយតម្លៃភាពអនុលោម និងមន្ទីរពិសោធន៍ ដែលនៅចំណុះវិទ្យាស្ថាន

- រៀបចំកិច្ចព្រមព្រៀង ឬ កិច្ចសន្យារបស់អង្គភាពវាយតម្លៃភាពអនុលោម មន្ទីរពិសោធន៍ធ្វើតេស្តឬក្រិតខ្នាត អង្គភាពបណ្តុះបណ្តាលសម្រាប់ការវាយតម្លៃភាពអនុលោម និងបុគ្គលណាមួយដែលមានលក្ខណសម្បត្តិដើម្បីវាយតម្លៃភាពអនុលោម និងសេវាកម្មនានា ពាក់ព័ន្ធនឹងការអនុវត្តតាមការតម្រូវនៃប្រព័ន្ធចេញវិញ្ញាបនបត្រ

ប្រការ ៥ : រាល់ប្រកាសនិងសេចក្តីសម្រេចទាំងឡាយណា ដែលមានន័យផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦ : អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងប្រធាននាយកដ្ឋានអភិវឌ្ឍស្តង់ដារ បណ្តុះបណ្តាល និងពិគ្រោះយោបល់ មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួនតាមប្រកាសនេះ ។

ប្រការ ៧ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០០៩

ស៊ុយ សែម

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

  "ដើម្បីជូនជ្រាប"
- គ្រប់នាយកដ្ឋានសេនាធិការក្រសួង
- គ្រប់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលរាជធានី-ខេត្ត

  "ដើម្បីជ្រាបជាព័ត៌មាន"
- ដូចប្រការ៦ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ភ្ជាប់ឧបសម្ព័ន្ធនៃប្រកាសលេខ ១១០៧ សហវ.ប្រក
ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៩

អង្គភាពលេខរបស់នាយកដ្ឋានបញ្ញត្តកម្មនិងវាយតម្លៃទទួលស្គាល់



បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៩
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ស៊ុយ សែម

បានឃើញ និង ពិនិត្យត្រឹមត្រូវ
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៩
ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា

ពីង ស៊ីវឡាយ

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៩
ប្រធាននាយកដ្ឋានបញ្ញត្តកម្ម
និងវាយតម្លៃទទួលស្គាល់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
inistry of Industry, Mines and Energy
លេខ : ១១៤៣ អ.ឧ.រ.ក.ប.រ

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០៩

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញលិខិតលេខ ១៨០៨/០៥ គ.វ.ក ចុះថ្ងៃទី០៨.០៦.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន អល ស៊ូបកើ អ៊ីនធើប្រាយ (ខេមបូឌា) ចុះថ្ងៃទី១៦.១១.២០០៩

សំរេច

ប្រការ១ :

-អនុញ្ញាតឱ្យក្រុមហ៊ុន អល ស៊ូបកើ អ៊ីនធើប្រាយ (ខេមបូឌា) តំណាងដោយ លោក HSU NAI-WEN សញ្ជាតិ ចិន(តៃវ៉ាន់) អាយុ៤៧ឆ្នាំ កាន់លិខិតឆ្លងដែនលេខ២០០១១៨៨៥៣ ចុះថ្ងៃទី ២០.១១.២០០២ មានអាសយដ្ឋាន បច្ចុប្បន្ន : លេខ3F.,No.7,Alley21, Lane 181,See.7, Jhongshan N.Rd., Shihlin District Taipei City តៃវ៉ាន់

111,Taiwan (ROC) ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រលើមុខសញ្ញា ដូចខាងក្រោម :

ឈ្មោះផលិតផល	លេខចុះបញ្ជីផលិតផល ISIC Code
សម្លៀកបំពាក់	៣២២០

-ផ្លាកឈ្មោះ រោងចក្រ : **អល ស៊ូបភើ អ៊ីនធើប្រាយ (ខេមបូឌា)**
ALL SUPER ENTERPRISE (CAMBODIA) LTD.

-ទីតាំងរោងចក្រ : *" ភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ "*

ប្រការ២ :

-ម្ចាស់រោងចក្រត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឱ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណាផ្សេងខុសពីមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណី ដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣ :

-ម្ចាស់រោងចក្រ ត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យ ដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសំរេចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម លេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានាស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤ :

ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬប្រគល់សិទ្ធិឱ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប៉ុន្តែក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និង គុណភាពផលិតផល របស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។/.

ក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និង គុណភាពផលិតផល របស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥ :

ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬ ចាត់ឱ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦ :

ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលសាធារណៈជនងាយមើលឃើញ ពីខាងមុខរោងចក្រ ។

ប្រការ៧:

-មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹង និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការ រោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឱ្យម្ចាស់រោងចក្រ មានសុពលភាព ០៣ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៈ

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពីនីតិរបាយការណ៍ និង ផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូ ដែល បានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់ទាន់ពេលវេលានូវកាតព្វកិច្ចបង់តម្លៃសេវាបញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ឆ្នាំ ។

ប្រការ៨ :

-ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហនៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាត ដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាពនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់ រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជា ស្វ័យប្រវត្តិ ។ ៗ៚

ប្រការ៩ :

-ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឱ្យអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយនៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅក្នុងអំឡុងពេលសប្តាហ៍ទីមួយនៃខែមករានៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រនឹងត្រូវទទួលទោសប្បញ្ញត្តិតាមមាត្រា ៤៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០:

